វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

NTFP-EP CAMBODIA
non-timber forest products – exchange programme

MRLG
MEKONG REGION LAND GOVERNANCE

សហការដោយ៖ NGOF និង NTFP-EP

គាំទ្រដោយ៖ MRLG

# របាយការណ៍សិក្សាស្រាវជ្រាវ ស្តីអំពី លទ្ធភាពនៃការគ្រប់គ្រងប្រវាក់ផ្គត់ផ្គង់ និង ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ












ភ្នំពេញ កម្ពុជា

**របាយការណ៍សិក្សាស្រាវជ្រាវ ស្តីអំពី លទ្ធភាពនៃការគ្រប់គ្រងច្រវាក់ផ្គត់ផ្គង់ និង ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ**

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែតុលា ឆ្នាំ២០២១
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីអភិបាលកិច្ចធនធានធម្មជាតិ
ស្រាវជ្រាវដោយ៖ រស់ សុដ្ឋា ទីប្រឹក្សាឯករាជ្យ
រចនាអត្ថបទដោយ៖ លោក ភួន យូ អ្នកសម្របសម្រួលសារព័ត៌មាន និងទំនាក់ទំនង

## សេចក្តីបញ្ជាក់៖

ទស្សនៈទាំងឡាយដែលបង្ហាញក្នុងរបាយការណ៍នេះ ជាទស្សនៈ និងការរកឃើញរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និង អង្គការ NTFP-EP Cambodia ព្រមទាំងម្ចាស់ជំនួយ MRLG ទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវបានដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការស្នើសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវបានឱ្យតម្លៃ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែតុលា ឆ្នាំ ២០២១**

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមទីប្រឹក្សាឯករាជ្យ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គល និងស្ថាប័នដូចមានរាយនាមខាងក្រោមដែលបានផ្តល់ការគាំទ្រដល់ការសិក្សានេះ។ ជាដំបូង យើងខ្ញុំសូមអរគុណចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ពិសេសកម្មវិធីអភិបាលកិច្ចធនធានធម្មជាតិ ដែលបានជួយគាំទ្រដំណើរការស្រាវជ្រាវ សហការ និងផ្តល់ធាតុចូល ដែលមានសារៈប្រយោជន៍សម្រាប់ការសិក្សានេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះមន្ត្រីរាជរដ្ឋាភិបាលនៃនាយកដ្ឋានពាក់ព័ន្ធសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលបានផ្តល់ព័ត៌មានដ៏មានសារៈសំខាន់ តាមរយៈការផ្តល់កិច្ចសម្ភាសន៍ និងពិគ្រោះយោបល់លើការសិក្សានេះ។

លើសពីនេះទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះសហគមន៍ព្រៃខ្មៅ សហគមន៍ដើមដូងក្នុងខេត្តកំពត សហគមន៍ពូជ្រៃ និងសហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹមក្នុងខេត្តមណ្ឌលគិរី សហគមន៍ព្រៃឈើគុណភាព១ សហគមន៍ព្រៃឈើគុណភាព២ សហគមន៍សង្កែ១ សហគមន៍កែថ្មែចង្កឹះឆែប១ ក្នុងខេត្តព្រះវិហារ សហគមន៍ភ្នំទ័ពជាងក្នុងខេត្តកោះកុង ដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុម និងផ្តល់ព័ត៌មានដ៏មានតម្លៃសម្រាប់ការស្រាវជ្រាវនេះ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារពិនិត្យ និងកែសម្រួលដែលមានសមាសភាពដូចជា លោក ឆឹង សុរិយ៉ា (NTFP-EP) លោក ជ័យ គូឡង់ (WWF) លោក ហួន ជុនឌី (CLEC) លោក សោម សុភ័ក្រ្ត (AFD) លោកស្រី សឿន សុភា (MVI) លោក ប៊ឹក សុភ័ណ (PKH) និងលោក ប៉ូច សុភ័ណ (MRLG) ដែលបានជួយពិនិត្យខ្លឹមសាររបាយការណ៍ និងផ្តល់មតិយោបល់ជាលក្ខណៈបច្ចេកទេសដើម្បីឱ្យរបាយការណ៍ល្អ។

ការសិក្សានេះពិតជាមិនអាចធ្វើទៅបានទេ ប្រសិនជាគ្មានការចូលរួមរបស់លោក លោកស្រី។

# មាតិកា


**មាតិកា** ..... i

**អក្សរកាត់** ..... iii

**សេចក្តីសង្ខេបប្រតិបត្តិ** ..... v

**សេចក្តីផ្តើម** ..... 1

១. សនិទានភាព ..... 1

២. ដំណើការ និងវិធីសាស្រ្ត ..... 4

៣. វិសាលភាព និងការកំណត់ ៖ ..... 7

**ការរកឃើញ** ..... 9

១. ស្ថានភាពទូទៅនៃក្របខណ្ឌគោលនយោបាយថ្នាក់ជាតិទាក់ទង នឹងអនុផលព្រៃឈើ.9

២. ឱកាសនៃ CF/CPA ដើម្បីកែប្រែអាជីវកម្មចិញ្ចឹមជីវិត និងការលូតលាស់ព្រៃឈើ តាមរយៈច្រវាក់ផ្គត់ផ្គង់ និងការបង្កលក្ខណៈ ដល់បរិស្ថាន ..... 12

**ក) ឱកាសទីផ្សាររួម៖** ..... 13

**ខ) ឱកាសទីផ្សារក្នុងស្រុក៖** ..... 19

**គ) ឱកាសទីផ្សារអន្តរជាតិ** ..... 21

៣. បញ្ហាជាក់ស្តែងប្រឈមដោយ CF/CPAs ក្នុងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ ហើយថាតើបញ្ហាទាំងនោះប៉ះពាល់ដល់ការគ្រប់គ្រងដោយនិរន្តរភាព នៃ CF/CPAs យ៉ាងដូចម្តេច ..... 24

៤. តើច្បាប់ និងគោលនយោបាយទាក់ទងនឹងអនុផលព្រៃឈើ និងការលើកលែងពន្ធអាចគួរត្រូវកែលម្អយ៉ាងដូចម្តេច ដើម្បីបង្ក     លក្ខណៈដល់ពាណិជ្ជកម្ម និងការប្រើប្រាស់អនុផលព្រៃឈើ ដោយនិរន្តរភាពដោយ CFs និង CPAs....................29

**សេចក្តីសន្និដ្ឋាន** ....................33

**អនុសាសន៍របស់អ្នកសិក្សាស្រាវជ្រាវ** ....................36

**ឧបសម្ព័ន្ធ** ....................41

ឧបសម្ព័ន្ធ១ ៖ ឯកសារយោង (ទិន្នន័យបន្ទាប់បន្សំ)....................41

ឧបសម្ព័ន្ធ ២៖ បញ្ជីបុគ្គលគន្លឹះដែលបានសម្ភាស....................44

ឧបសម្ព័ន្ធ៣៖ វគ្គមានក្រុមពិភាក្សា....................49

ឧបសម្ព័ន្ធ៤ ៖ ដំណើរការជាក់ស្តែងក្នុងការស្នើសុំនាំចេញផលិតផល អនុផលព្រៃឈើ .53

ឧបសម្ព័ន្ធ៥ ៖ ព័ត៌មានបន្ថែមអំពីចំណូលពីអនុផលផ្សេងៗទៀត....................55

- *ក្រាហ្វិចទី១៖ ការពន្យល់ និងវិភាគអំពីឱកាសនិងឧបសគ្គនៃទីផ្សារក្នុងស្រុកនិងអន្តរជាតិ នៃផលិតផលអនុផលព្រៃឈើកម្ពុជា (ទំព័រទី ១២)*
- *ក្រាហ្វិចទី២៖ ច្រវាក់ផ្គត់ផ្គង់ - ឧត្តមានុវត្តន៍ (ទំព័រទី ២២ និង ២៣)*
- *ក្រាហ្វិចទី៣៖ ដើមឈើបញ្ហា ការវិភាគ និងរូបបង្ហាញនូវបញ្ហាជាក់ស្តែងបំផុត ប្រឈមដោយសហគ្រាសអនុផលព្រៃឈើ (ទំព័រទី ២៤)*

# អក្សរកាត់

| | |
|---|---|
| AAC | សមាគមសិល្បករកម្ពុជា |
| CF | សហគមន៍ព្រៃឈើ |
| CPA | សហគមន៍តំបន់ការពារធម្មជាតិ |
| CSO | អង្គការសង្គមស៊ីវិល |
| EC | គណៈកម្មការអឺរ៉ុប |
| EMC | ការប្រឹក្សាអំពីទីផ្សារកំពុងលេចឡើង (Emerging Markets Consulting) |
| FA | រដ្ឋបាលព្រៃឈើ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| FLEGT | ការអនុវត្តច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម (Forest Law Enforcement, Governance, and Trade) |
| IKEA | Ingvar Kamprad Elmtaryd Agunnaryd (Swedish, Furniture retail company) ក្រុមហ៊ុនលក់រាយគ្រឿងសង្ហារិម |
| INBAR | អង្គការផ្តៅ និងឫស្សីអន្តរជាតិ |
| LF | ច្បាប់ព្រៃឈើ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoE | ក្រសួងបរិស្ថាន |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| MFV | ព្រៃឈើមណ្ឌលគិរី |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| MRLG | អភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ |
| NTFP | ផលិតផលអនុផលព្រៃឈើ |
| NTFP-EP | អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ព្រៃឈើនៅកម្ពុជា |
| RAC | សមាគមផ្តៅ និងឫស្សី កម្ពុជា |
| SDCFM | អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអែត (Swedish International Development Agency) |
| SIE | សហគ្រិនដែលចំណូលចិត្តពីធម្មជាតិ |
| ToR | ក្របខណ្ឌការងារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ |
| V4MF | សំឡេងដើម្បីព្រៃឈើមេគង្គ (Voices for Mekong Forests) |
| WB | ធនាគារពិភពលោក |

# សេចក្តីសង្ខេបប្រតិបត្តិ

ទីផ្សារក្នុងស្រុក និងអន្តរជាតិនៃផលិតផលអនុផលព្រៃឈើកាន់តែមានតម្រូវការច្រើនឡើងៗ ពិសេសសម្រាប់ឫស្សី ដោយសារការយល់ដឹងពីបរិស្ថាន ឈើកាន់តែក្រ តម្លៃកាន់តែខ្ពស់ ហើយអតិថិជនចង់បាននូវអ្វីៗដែលថ្មី និងប្លែកៗ។ ជាមួយនឹងភាពស្រស់ស្អាត ឫស្សីមានផលប្រយោជន៍ ពាណិជ្ជកម្មប្រកបដោយសក្តានុពលសម្រាប់ទីផ្សារ ដោយសារវាអាចប្រើប្រាស់ និងកែច្នៃជាសម្ភារៈយ៉ាងច្រើនប្រភេទ ដែលពិភពលោកកំពុងប្រើប្រាស់ជារៀងរាល់ថ្ងៃ ដូចជា សម្ភារៈសំណង់ផ្ទះ វត្ថុតម្បាញ គ្រឿងសង្ហារិម ក្រដាស់ ក្រដាស់អនាម័យ របស់របរសម្រាប់ទុកដាក់អីវ៉ាន់ ជាឈើច្នៃសម្រាប់ធ្វើផ្ទះ ដូចជាកម្រាល ជញ្ជាំង ។ល។ ខណៈផ្តៅកំពុងតែរិចរិល ឫស្សីអាចជាវត្ថុជំនួសវា និងឈើទាំងឡាយ។ វាជារុក្ខជាតិ ដែលដាំដុះបានលឿនទៀតផង។ សហគ្រាសអនុផលព្រៃឈើរបស់សហគមន៍ព្រៃឈើ (CF) ឬសហគមន៍តំបន់ការពារធម្មជាតិ (CPA) អាចផ្គត់ផ្គង់វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងផលិតផលសម្រេចដល់អ្នកទិញផ្សេងៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ទីផ្សារអន្តរជាតិ ត្រូវការកិច្ចខិតខំប្រឹងប្រែងរយៈពេលវែងលើការនាំចេញអនុផលព្រៃឈើដែលស្របច្បាប់។ ដូច្នេះ ដើម្បីឆ្លើយតបនឹងតម្រូវការជាប្រចាំថ្ងៃ និងស្ថានភាពបច្ចុប្បន្ន យើងគួរធ្វើការផ្តោតលើការបំពេញតម្រូវការ និងការចង់បានអនុផលព្រៃឈើសម្រាប់ទីផ្សារក្នុងស្រុក ដែលមិនទាន់បានបំពេញនៅឡើយ ខណៈដែលសមត្ថភាព និងលទ្ធភាពនៃការនាំចេញនៅជាការប្រឈមនៅឡើយនាពេលឥឡូវនេះ។

សម្រាប់ទីផ្សារអន្តរជាតិ ជាការប្រសើរ សហគ្រាសអនុផលព្រៃឈើ ឬ CF/CPAs គួរធ្វើការផ្គត់ផ្គង់នូវវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចនានាទៅឲ្យក្រុមហ៊ុននាំចេញ ឬ ក្រុមហ៊ុនវិនិយោគបរទេស។ ចំពោះទីផ្សារក្នុងស្រុកវិញ CF/CPAs ឬ សហគ្រាសអនុផលព្រៃឈើ អាចផ្គត់ផ្គង់នូវវត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសម្រេចដល់សហគ្រាសកែច្នៃអនុផលព្រៃឈើ និងផលិតផលសម្រេចអាចត្រូវផ្គត់ផ្គង់ ទៅអ្នកប្រើប្រាស់ជាបុគ្គល ដែលរួមមានអាជីវកម្មអេកូទេសចរណ៍ មណ្ឌលកម្សាន្ត ជនបរទេស និងគ្រួសារជាអ្នកមាន និងកម្រិតកណ្តាល។

សហគ្រាសអនុផលព្រៃឈើដែលជោគជ័យចាប់ផ្តើមពីបុគ្គល ដែលមានចំណូលចិត្តលើផលិតកម្មអនុផលព្រៃឈើណាមួយ។ គាត់អាចដឹកនាំបុគ្គល និងសហគ្រាសរួម ហើយច្រើនតែបានជោគជ័យ។ សហគ្រិនបែបនេះអាចដឹកនាំ និងជាអ្នកគាំទ្រ និងអ្នកទិញល្អសម្រាប់សមាជិកសហគមន៍ និងផលិតករ ឬអ្នកប្រមូលទិញអនុផលព្រៃឈើនានា។

អង្គការពាណិជ្ជកម្មអនុផលព្រៃឈើ ដែលមាននិរន្តរភាព គឺជាអង្គការមានសមាហរណកម្មរវាងកិច្ចខិតខំប្រឹងប្រែងរួមនិងឯកជន ហើយចែករំលែកផលចំណេញ ឬផលប្រយោជន៍គ្នាទៅវិញទៅមក។ វាមិនអាចសម្រេចបានដោយឲ្យតែសហគ្រាសអនុផលព្រៃឈើសហគមន៍ធ្វើតែម្នាក់ឯងបានឡើយ។ ឧទាហរណ៍ ការចែករំលែកទីផ្សារ និងការគ្រប់គ្រងនូវទីតាំង ដែលអាចចេញចូលបាន មានអ្នកលក់ ដែលបានចាត់តាំងពីគណៈកម្មការសហគ្រាស (តែគាត់នៅតែបង់ប្រាក់ឲ្យសហគ្រាសសហគមន៍) តាមកម្រិតសមរម្យ និងឯកភាពគ្នាណាមួយ ។ល។

ដើម្បីអាចប្រកួតប្រជែងបាន សហគ្រាសត្រូវមានអ្នកមានបទពិសោធន៍ និងជំនាញបច្ចេកទេសខ្ពស់ មានម៉ាស៊ីន ឬឧបករណ៍ដែលអាចធានាបានផលិតផលសមរម្យ និងមានជំនាញអាជីវកម្ម ពិសេសទីផ្សារ ឬការលក់ ការធ្វើផែនការមុខរបរ និងការគ្រប់គ្រងថវិកា។

មានការលើកលែងពន្ធជាច្រើនសម្រាប់ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើនាពេលបច្ចុប្បន្ន ពិសេសការលក់ និងនាំចេញផលិតផលអនុផលព្រៃឈើ មានការកែច្នៃ យោងតាមតារាងពន្ធគយ ២០១៧ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា។ យោងតាមតារាងពន្ធគយ រដ្ឋលើកកម្ពស់ការកែច្នៃអនុផលព្រៃឈើជាជាងការលក់វត្ថុធាតុដើម។ ឧទាហរណ៍ រដ្ឋយកពន្ធ ១០% លើការនាំចេញឫស្សី និងផ្តៅឆៅ តែយកតែ៥%ទេ លើគ្រឿងសង្ហារិម តុ និងទូ និងសម្ភារៈលើតុ ដូចជាចង្កឹះ ស្លាបព្រា វែក ចាន ។ល។ រដ្ឋមិនយកពន្ធអ្វីទាំងអស់សម្រាប់ការនាំចេញកៅអី និងផលិតផលតម្បាញធ្វើអំពីផ្តៅ និងឫស្សី រួមទាំងទឹកឃ្មុំ និងជ័រទឹក។ រដ្ឋបាលព្រៃឈើ ឬ MAFF និង ក្រសួងបរិស្ថានមានឆន្ទៈផ្តល់ការរួចពន្ធលើថ្លៃសួយសារ និងបុព្វលាភលើការប្រមូលផលអនុផលព្រៃឈើមិនទាន់សម្រេចចេញពី CF ឬ CPAs ទាំងឡាយណាដែលទទួលបាននូវផែនការប្រមូលផលដោយចីរភាពដែលបានអនុញ្ញាតហើយ។

មានបញ្ហាប្រឈមផ្នែកគោលនយោបាយមួយចំនួន ដែលនៅតែជាឧបសគ្គក្នុងការលើកកម្ពស់សិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ និងចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទីមួយ រយៈពេលនៃការចាត់ចែង CF/CPAs ដែលអនុញ្ញាតហើយគឺបានត្រឹមតែ ១៥ឆ្នាំប៉ុណ្ណោះ ការបន្តគឺជាប្រធានបទ ដែលត្រូវពិនិត្យឡើងវិញ ដូច្នេះការវិនិយោគរយៈពេលវែងពិបាកនឹងធ្វើណាស់។ វាក៏ជះឥទ្ធិពលដល់ការលើកទឹកចិត្តដល់សហគមន៍ផងដែរ។ ទីពីរ CF/CPAs មិនអាចចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនណាមួយសម្រាប់ការវិនិយោគរយៈពេលវែងក្នុងការលើកកម្ពស់ជីវភាពសហគមន៍ និងការអភិវឌ្ឍមូលដ្ឋានចេញពីធនធានព្រៃឈើ និងធនធាន ដែលពាក់ព័ន្ធបានឡើយ។ ទីបី ទាំងអ្នកភូមិ សហគមន៍ CF/CPA មានសិទ្ធិប្រើប្រាស់អនុផលព្រៃឈើ ប៉ុន្តែពួកគេមិនមានសិទ្ធិដឹកជញ្ជូនទៅទីផ្សារបានទេ។ ដែនកំណត់នេះហើយធ្វើឱ្យពាណិជ្ជកម្ម CF/CPA មានភាពលំបាកស្មុគស្មាញ និងចំណាយពេលច្រើនសម្រាប់បរិបទនៃប្រទេសកម្ពុជា។ ទីបួន រាជរដ្ឋាភិបាលបានធ្វើការលើកលែងពន្ធជាច្រើន ប៉ុន្តែសហគមន៍ទាំង CF និង CPA នៅតែត្រូវការស្នើសុំការលើកលែងពន្ធលើថ្លៃសួយសារ និងបុព្វលាភ សម្រាប់ការប្រមូលផលអនុផលព្រៃឈើ ដោយផ្អែកលើច្បាប់ស្តីពីព្រៃឈើ។ ដូច្នេះ វាគួរតែត្រូវបានអនុវត្តស្របតាមគោលនយោបាយជាតិដែលត្រូវបានបង្កើតឡើង។ ជាសរុបមក ចំណុចសំខាន់ៗទាំងអស់នេះចាំបាច់ត្រូវយកមកពិចារណាដើម្បីធ្វើវិសោធនកម្មគោលនយោបាយ ឬច្បាប់ដែលមានជធរមាន។

ទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិ សហគ្រាស ឬក្រុមហ៊ុនអនុផលព្រៃឈើកម្ពុជាជួបប្រទះនូវការប្រឈមចំនួនប្រាំមួយចំណុចដូចខាងក្រោម៖

- ខ្វះសហគ្រិនដែលមានចំណង់ចំណូលចិត្តលើការធ្វើ និងដឹកនាំសហគ្រាសអនុផលព្រៃឈើ
- ជំនាញបច្ចេកទេសនៅអន់ខ្សោយ និងទាប
- ឧបករណ៍ និងម៉ាស៊ីនកែច្នៃនៅមិនទាន់ និងមិនទាន់ទំនើប
- ការយកថ្លៃក្រៅផ្លូវការមានតម្លៃខ្ពស់
- គុណភាពផលិតផលនៅអន់
- ប្រឈមមុខនឹងវត្ថុធាតុដើមដែលមិនគ្រប់គ្រាន់ ពិសេសផ្តៅ ទឹកឃ្មុំ ដោយសារ ការកាប់ព្រៃឈើ និងការប្រមូលផលដោយអនាធិបតេយ្យនៅកន្លែងមួយចំនួន។

នៅមានបញ្ហាប្រឈមជាច្រើនដែលមិនលើកទឹកចិត្តដល់ការនាំចេញ ឬក្រុមហ៊ុនវិនិយោគបរទេសខ្នាតធំមកវិនិយោគនៅកម្ពុជា។ នីតិវិធី និងទម្លាប់នៃការអនុវត្តការនាំចេញមានភាពស្មុគស្មាញ និងវែងឆ្ងាយ កង្វះបទពិសោធន៍នាំចេញ (ក្រុមហ៊ុនខ្មែរ) និងមានភាពជាដៃគូ ដែលមានកំណត់ជាមួយដៃគូរដ្ឋាភិបាល និងក៏ដូចជារវាងរដ្ឋាភិបាល និងក្រុមហ៊ុន។ នៅទីផ្សារក្នុងស្រុក សហគ្រាស NTFP បច្ចុប្បន្នមានបញ្ហាប្រឈមមួយចំនួន ដែលនាំឱ្យការផ្គត់ផ្គង់មានកម្រិតទាបនៅលើទីផ្សារ។ ពួកគេខ្វះព័ត៌មានអំពីទីផ្សារ និងខ្វះយុទ្ធសាស្ត្រប្រកួតប្រជែងជាពិសេសសម្រាប់ផ្កា ទឹកឃ្មុំ និងផលិតផលទ្រាំង។

ដើម្បីជំនះរាល់ឧបសគ្គនៃការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព អ្នកស្រាវជ្រាវបានចងក្រង និងផ្តល់ជាង១០អនុសាសន៍ ដូចខាងក្រោម៖

## អនុសាសន៍រួមសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសសហគ្រិនទាំងឡាយ៖

i. អ្នកពាក់ព័ន្ធក្នុងការធ្វើពាណិជ្ជកម្មនៃអនុផលព្រៃឈើ គួរតែផ្តោតលើការពង្រឹង និងពង្រីកពាណិជ្ជកម្មផលិតផលអនុផលព្រៃឈើសម្រាប់ទីផ្សារក្នុងស្រុកជាអាទិភាពទី១ មុនពេលឈានជើងចូលទីផ្សារអន្តរជាតិ។ មានតម្រូវការ និងការចង់បានជាច្រើនដើម្បីបំពេញក្នុងចំណោមអតិថិជនដែលមានស្រាប់ និងពង្រីកការលក់ក្នុងចំណោមអ្នកមាន និងអ្នកមធ្យមនៅប្រទេសកម្ពុជា។ ការវេចខ្ចប់ត្រឹមត្រូវ គួរតែត្រូវបានធានា និងបញ្ចូលជាមួយនូវស្លាកបៃតង និងការលក់តាមអ៊ិនធឺណេត និងទីផ្សារឌីជីថល (online and digital marketing) ឱ្យបានត្រឹមត្រូវ ជាពិសេសតាមរយៈហ្វេសប៊ុក។ គួរពិចារណានូវមុខនាទីអ្នកជំនាញខាងទីផ្សារ និងលក់ត្រឹមត្រូវណាមួយមកឲ្យជួយបំពេញ ក្នុងតម្រូវការនេះ និងផ្តល់ការគាំទ្រជាយុទ្ធសាស្ត្រ;

ii. ដោយសារមានគោលនយោបាយលើកលែងពន្ធច្រើន អ្នកពាក់ព័ន្ធនៃអនុផលព្រៃឈើគួរតែបង្វែរកិច្ចខំប្រឹងប្រែងរបស់ខ្លួនពីការស្វែងរកមធ្យោបាយសុំការលើកលែងពន្ធ ទៅនីតិវិធីងាយស្រួលសម្រាប់ការនាំចេញវិញ;

iii. ឆ្លៀតឱកាសដែលនឹងមកដល់នៃការធ្វើវិសោធនកម្មច្បាប់ ទាំងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, ភាគីពាក់ព័ន្ធអនុផលព្រៃឈើគួរតែ៖

- ➢ គស៊ូមតិដើម្បីសម្រួលរយៈពេលនៃដំណើរការអនុវត្ត CF/CPAs ឲ្យបាន យ៉ាងហោចណាស់ ៣០ ឆ្នាំជំនួសឱ្យរយៈពេល ១៥ឆ្នាំដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការវិនិយោគរយៈពេលវែង រួមទាំងការច្នៃប្រឌិតប្រាក់ចំណូល CF/CPA ក្នុងការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើ។
- ➢ គស៊ូមតិដើម្បីពង្រីកសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងដំណើរការអនុវត្ត CF/CPAs ដើម្បីអាចចុះកិច្ចសន្យាជាមួយអង្គការវិស័យឯកជនក្នុងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ និងការវិនិយោគរយៈពេលវែងដែលពាក់ព័ន្ធដូចជាការដាំរុក្ខជាតិឧស្សាហកម្មនៅលើដីរេចរឹល ឬតាមរបៀបចម្រុះ ការដាំឈើមានគុណភាព និងដំណាំឧស្សាហកម្ម ជាដើម ដែលអាចជួយរកប្រាក់ចំណូលបានច្រើនសម្រាប់ជីវភាព និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន។
- ➢ ក្នុងការពង្រីកសិទ្ធិរបស់សហគមន៍មូលដ្ឋាន CF/CPAs សហគមន៍អនុផលព្រៃឈើគួរតែរកការគាំទ្រដើម្បីមានសិទ្ធិដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារផងដែរ។
- ➢ អ្នកពាក់ព័ន្ធនៃអនុផលព្រៃឈើគួរតែស្វែងរកការគាំទ្រដើម្បីទទួលបានលើកលែងថ្លៃបុព្វលាភ និងកម្រៃជើងសាសម្រាប់សហគមន៍ CF/CPAs ដែលទទួលបានការឯកភាពលើផែនការប្រមូលផលប្រកបដោយនិរន្តរភាព។

យោងតាមការរកឃើញ កម្រិតនៃជោគជ័យនៃការងារនេះគឺមានកម្រិតខ្ពស់ ព្រោះចំណុចទាំងនេះកំពុងត្រូវបានពិនិត្យលើការធ្វើវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិនៅឯក្រសួងបរិស្ថាន និងការធ្វើវិសោធនកម្ម ច្បាប់ស្តីពីព្រៃឈើ ដែលគ្រោងធ្វើនៅឆ្នាំ២០២៣ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងមហាផ្ទៃ;

iv. កិច្ចខិតខំប្រឹងប្រែងរួមគ្នា៖ សហគ្រាសអនុផលព្រៃឈើមានមូលដ្ឋាននៅសហគមន៍ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលគួរតែធ្វើការរួមគ្នាដើម្បីលើកកម្ពស់ដំណើរការ និងការនាំចេញផលិតផលអនុផលព្រៃឈើ។ អង្គការសង្គមស៊ីវិលគួរតែសិក្សាពីផែនការដែលមានស្រាប់របស់រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ហើយចូលរួម និងជួយបង្កលទ្ធភាពឱ្យពួកគេអនុវត្តគម្រោងបានកាន់តែប្រសើរ។ គម្រោងដែលមានកិច្ច

សហការបែបនេះអាចត្រូវបានអនុវត្ត និងបន្តទៅមុខជាជំហានៗ និងផ្អែកតាមមូលដ្ឋាននៃលទ្ធផល (outcome based)។ តួអង្គនីមួយៗ ដើរតួទៅតាមតួនាទីខុសៗគ្នាតាមសមរម្យ។ ឧទាហរណ៍សហគមន៍ ឬសហគ្រាសអនុផលព្រៃឈើទទួលខុសត្រូវក្នុងការគ្រប់គ្រង និងផ្គត់ផ្គង់ធនធាន ឬផលិតផលអនុផលព្រៃឈើ។ រដ្ឋាភិបាលគួរតែទទួលខុសត្រូវក្នុងការគាំទ្រការដឹកជញ្ជូន នីតិវិធីនាំចេញ និងកិច្ចការរដ្ឋបាល ឬការសម្របសម្រួលពាក់ព័ន្ធនឹងអនុផលព្រៃឈើ និងស្វែងរកទីផ្សារ។ ការបន្ថែម អង្គការសង្គមស៊ីវិលគួរតែទទួលខុសត្រូវក្នុងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងក្នុងការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ ហើយវិស័យឯកជនគួរតែទទួលខុសត្រូវលើការកែច្នៃ និងនាំចេញ។ ដើម្បីជានាកុំឲ្យមានទំនាស់ផលប្រយោជន៍ ការធ្វើសេចក្តីសម្រេចបែបប្រជាធិបតេយ្យគួរតែធ្វើឡើងដើម្បីធ្វើគោលនយោបាយ និងការគ្រប់គ្រងប្រតិបត្តិការសំខាន់ៗ។ គម្រោងគួរតែមានក្រុមប្រឹក្សាភិបាលរួមមួយ ដែលមានសំឡេងស្មើគ្នាដើម្បីធ្វើការសម្រេច និងមានគណៈកម្មាធិការប្រតិបត្តិការ និងគណៈកម្មាធិការបច្ចេកទេសរួមគ្នា។ វានឹងលើកកម្ពស់ភាពជាម្ចាស់ពិតប្រាកដនិងជំនះឧបសគ្គក្នុងការលើកកម្ពស់វិស័យនេះ ឱ្យកាន់តែប្រសើរឡើង។ គំនិតនេះអាចត្រូវបានចាប់ផ្តើមដោយគម្រោងសាកល្បង មានការវាយតម្លៃ និងពង្រីកតាមតម្រូវការជាក់ស្តែង;

v. នៅតែមានតម្រូវការចាំបាច់ដើម្បីឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការអភិរក្ស និងដាំដើមឈើឡើងវិញដើម្បីធ្វើឲ្យមានភាពសម្បូរបែបនូវប្រព័ន្ធអេកូឡូស៊ី និងធនធានអនុផលព្រៃឈើ។ នេះអាចធ្វើទៅបានតាមរយៈភាពជាដៃគូ និងការតស៊ូមតិរួមគ្នា។ ដំណោះស្រាយរួមគ្នាគួរតែឆ្លុះបញ្ចាំងពីបញ្ហាពិត ដែលកំពុងកើតឡើងនៅថ្នាក់មូលដ្ឋាន ឬ សហគមន៍ដូចជាការទន្ទ្រានយកដី និងការប្រមូលផលអនាធិបតេយ្យនៅក្នុងតំបន់ CF និង CPAs។ ការបញ្ឈប់ការកាប់ ទុកឱកាសឲ្យឈើដុះឡើងវិញជាដំណោះស្រាយល្អបំផុត។ ទោះយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវធ្វើដោយមានការគាំទ្រពី FA និង MoE ដោយមានការចូលរួម ពីសហគមន៍ទាំងឡាយ; និង

vi. ការដាំដើមឈើដែលមានគុណភាពនិងសម្រាប់ឧស្សាហកម្មនៅក្នុងតំបន់ដែលមានការរិចរឹលក្នុង CF/CPAs បានក្លាយជាសញ្ញាលេចធ្លោនៃប្រភពចំណូលដែលមានសក្តានុពល និងជុំកំភួនសម្រាប់សហគមន៍។ ទោះជាយ៉ាងណា វាជាប្រធានបទត្រូវ

សិក្សាបន្ថែម និងធ្វើឱ្យប្រាកដថាសកម្មភាពប្រភេទនេះអាចគាំទ្រ CF /CPAs ឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

i. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាគួរតែបង្កើនការគាំទ្រឱ្យបានច្រើនដល់ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើនៃ CFs ឬ CPAs តាមរយៈការបង្កើនធាតុចូលរបស់ខ្លួនក្នុងការវិនិយោគហិរញ្ញវត្ថុសម្រាប់ការបង្កើនដើមទុន និងគ្រឿងម៉ាស៊ីនទំនើបៗ ការកៀរគរអ្នកវិនិយោគ ឬអ្នកទិញមកពីជុំវិញពិភពលោក តាមរយៈការទូត និងបណ្តាញរបស់ខ្លួនដោយបង្កើតវិធីសាមញ្ញសម្រាប់ការអនុញ្ញាតនាំចេញ។ ផ្តល់ការគាំទ្រ និងការការពារផ្នែករដ្ឋបាលនៅតាមដងផ្លូវដល់ការដឹកជញ្ជូនផលិតផលអនុផលព្រៃឈើ គឺត្រូវប្រាកដថាមិនមានការសម្របសម្រួលខ្សោយ និងបញ្ហាការបង់ប្រាក់ក្រៅផ្លូវការពីមន្ត្រីរដ្ឋាភិបាល ដែលពាក់ព័ន្ធ និងនីតិវិធីសាមញ្ញសម្រាប់ការនាំចេញ;

ii. ដើម្បីឲ្យស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលលើកលែងពន្ធនាំចេញ ច្បាប់ (ព្រៃឈើ; តំបន់ការពារធម្មជាតិ) គួរតែអនុញ្ញាតឱ្យ CF និង CPAs ដែលបានអនុញ្ញាតហើយមានផែនការប្រមូលផលប្រកបដោយនិរន្តរភាពដើម្បីទទួលបានការមិនយកថ្លៃបុព្វលាភ និងកម្រៃជើងសាដោយស្វ័យប្រវត្តិ ខណៈច្បាប់ព្រៃឈើកំពុងត្រូវបានធ្វើវិសោធនកម្ម។ បង្កើនរយៈពេលនៃការអនុញ្ញាតឱ្យដំណើរការ CF/CPAs ដែលមានការអនុញ្ញាតដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការប្តេជ្ញាចិត្តយូរអង្វែងរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ និងអនុញ្ញាតឱ្យពួកគេអាចចុះកិច្ចសន្យាវិនិយោគជាមួយវិស័យឯកជនដើម្បីលើកកម្ពស់អនុផលព្រៃឈើ និងសកម្មភាពពាណិជ្ជកម្ម ដែលអាចធ្វើបាន ដូចជាបន្ត និង ពង្រីកកសិ-រុក្ខកម្ម ការដាំដើមឈើថ្មីៗតាមវិធីសាស្ត្រចម្រុះ ឬនៅតំបន់រេចរឹលនានា។ល។ បន្ថែមសេចក្តីពិពណ៌នាឲ្យបានកាន់តែច្បាស់ថា CF/CPAs ដែលមានផែនការប្រមូលផលប្រកបដោយនិរន្តរភាពអាចដឹកជញ្ជូនផលិតផលអនុផលព្រៃឈើរបស់ពួកគេទៅកាន់ទីផ្សារ;

iii. នីតិវិធីនៃការនាំចេញ៖ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានភាពសាមញ្ញលើនីតិវិធីនៃការនាំចេញ ពោលគឺ ខ្ពស់បំផុតការអនុញ្ញាតឲ្យការនាំ

ចេញគួរតែត្រូវបានធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឱ្យទីស្តីការគណៈរដ្ឋមន្ត្រី;

iv. គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអនុផលព្រៃឈើគួរត្រូវបានសរសេរឡើង ដើម្បីណែនាំ CF/CPAs និងអ្នកពាក់ព័ន្ធរបស់ពួកគេអំពីរបៀបគ្រប់គ្រង និងដំណើរការសហគ្រាស NTFP ដើម្បីឲ្យពួកគេមានគំនិត ឬ រូបភាពច្បាស់លាស់លើបញ្ហានេះដោយមិនអនុវត្តផ្ទុយ ឬរំលោភលើច្បាប់ ឬ អនុក្រឹត្យពាក់ព័ន្ធនឹងព្រៃឈើ; និង

v. រាជរដ្ឋាភិបាលកម្ពុជាគួរបំបែកអនុផលព្រៃឈើចេញពីបញ្ជីឈើ (timber list) នៅក្នុងឯកសារច្បាប់ ដែលវាជួយឱ្យដំណើរការនិងនីតិវិធីធ្វើពាណិជ្ជកម្មមានភាពងាយស្រួល និងសាមញ្ញ។

## អនុសាសន៍សម្រាប់ភ្នាក់ងារគាំទ្រទាំងឡាយ៖

i. ខណៈពេលដែលកំពុងផ្សព្វផ្សាយអនុផលព្រៃឈើនៅក្នុងទីផ្សារក្នុងស្រុក ភ្នាក់-ងារគាំទ្រអនុផលព្រៃឈើ គួរបន្តការលើកកម្ពស់វិនិយោគិនបរទេសឱ្យធ្វើការ វិនិយោគនៅក្នុងការផលិតឬកែច្នៃឧស្សាហកម្មខ្នាតយក្ស ហើយដែលមាន លក្ខណៈស្អាត ឬបៃតងផង។ ភ្នាក់ងារគាំទ្រនៃអនុផលព្រៃឈើ គួរតែផ្តល់ ព័ត៌មានដល់ក្រុមហ៊ុន និងវិនិយោគិនយក្ស (អន្តរជាតិ) ជាថ្មីម្តងទៀតអំពី ការប្រែប្រួលលើការលើកលែងពន្ធ ជាពិសេសអនុផលព្រៃឈើ ដែលមានការកែច្នៃ និងលើកទឹកចិត្តអ្នកដែលមានសក្តានុពលឱ្យចាប់ផ្តើមកែច្នៃ និងនាំចេញ;

ii. ការសម្របសម្រួល និងគាំទ្រសហគ្រាស ឬ ក្រុមហ៊ុនអនុផលព្រៃឈើគួរតែត្រូវ បានសម្របសម្រួលដោយយកចិត្តទុកដាក់លើចំណុចចីរភាព ដូចជាថ្លៃឈ្នួលប្រាក់ខែ និងចំណាយប្រតិបត្តិការផ្សេងទៀត ដូចជាទីតាំងការិយាល័យដែលមានតម្លៃថ្លៃ ឬ ការជួលជាដើម។ មធ្យោបាយល្អបំផុតគឺចូលរួមប្រើប្រាស់ធនធានដែលមានស្រាប់របស់សហគមន៍ ឬសមាជិកម្នាក់ៗ ដោយការចែករំលែកនូវអត្ថប្រយោជន៍ទៅវិញទៅមកដែលអាចធ្វើទៅបាន។

# សេចក្តីផ្តើម

## ១. សនិទានភាព

ជាប្រពៃណីប្រជាជនកម្ពុជាភាគច្រើនពឹងផ្អែកលើផលិតផលព្រៃឈើដែលជាមធ្យោបាយនៃការចិញ្ចឹមជីវិតរបស់ពួកគេ។ ផ្ទៃដីសរុប ១៨,១ លានហិកតានៃប្រទេសកម្ពុជាដែលភាគច្រើនគ្របដណ្តប់ដោយដីព្រៃជាច្រើនពាសពេញតំបន់អេកូឡូស៊ីហើយប្រជាពលរដ្ឋបានរួមបញ្ចូលជីវិតនិងព្រៃឈើ។ ពាក្យមួយទៀត ព្រៃបានចិញ្ចឹមប្រជាជនកម្ពុជាតាំងពីអតីតកាល។ ព្រៃឈើថែមទាំងគ្របដណ្តប់លើផ្ទៃដីកម្ពុជាជាង ៧០% ក្នុងកំឡុងឆ្នាំ ១៩៦០។ ទោះបីជាវាត្រូវបានបំផ្លាញភាគច្រើនក៏ដោយ ពលរដ្ឋកម្ពុជានៅតែមានចំនួន ៦៨% ពឹងផ្អែកលើធនធានអនុផលព្រៃឈើដែលជាផ្នែកមួយនៃមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេ[1]។ នេះអំពាវនាវថាការអភិវឌ្ឍវិស័យអនុផលព្រៃឈើនៅកម្ពុជាមានភាពចាំបាច់។

នាពេលបច្ចុប្បន្ននេះប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមផ្អែកលើទិន្នន័យឆ្នាំ ២០១៩ របស់អង្គការ WWF មាន ១៧ សហគមន៍ (CPAs/CFs) ដែលកំពុងត្រូវបានគាំទ្រដោយអង្គការនេះ រកប្រាក់ចំណូលបាន ១.៣៣២.០០០ ដុល្លារតាមរយៈការលក់ផលិតផលកែច្នៃចេញពីអនុផលព្រៃឈើ។ សព្វថ្ងៃនេះមាន CF ចំនួន ៤៨៤ ត្រូវបានបង្កើតឡើង ស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង CPA ចំនួន ១៦៣ ត្រូវបានបង្កើតឡើង ក្រោមក្រសួងបរិស្ថាននៅកម្ពុជា (ទិន្នន័យឆ្នាំ ២០២០)។ សហគ្រាសអនុផលដទៃទៀតរកប្រាក់ចំណូល

---

[1] គេហទំព័រ៖ សហគ្រាសអនុផលព្រៃឈើ (NTFP-based enterprises) ដោយសហគមន៍ជនបទដើម្បីលើកទឹកចិត្ត សម្រាប់ការការពារបរិស្ថាន និងសង្គម ១០មិថុនា ២០១៩។

បានជាច្រើន ដូចជា AAC និងRAC[2] រួមទាំងសហគ្រាសក្រៅផ្លូវការ និងមិនត្រូវបានចុះឈ្មោះនៅក្នុងព្រះរាជណាចក្រកម្ពុជា[3]។

ឡាវទទួលបានប្រាក់ចំណូល ២៣ ភាគរយនៃប្រាក់ចំណូលគ្រួសាររបស់ពួកគេពីបរិស្ថានដែលអនុផលព្រៃឈើបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងផ្នែកនោះ។ ទោះបីជាមានស្ថិតិមិនច្បាស់អំពីប្រាក់ចំណូលរបស់អនុផលព្រៃឈើក៏ដោយ ក៏ប្រទេសកម្ពុជាទទួលបានថវិកាប្រហែល ៤ លានដុល្លារក្នុង១ឆ្នាំ ពីអនុផលព្រៃឈើ ខណៈវិស័យនេះនៅតែមិនទាន់មានការអភិវឌ្ឍនៅឡើយ។

ផ្អែកលើលទ្ធផលនៃការសិក្សានិងការពិភាក្សាពីមុនរបស់អង្គការ WWF និងភាគីពាក់ព័ន្ធ ឧទាហរណ៍វេទិកា អនុផលព្រៃឈើថ្នាក់ជាតិលើកទី ១ និងលើកទី ២ បានបង្ហាញថាវិស័យអនុផលព្រៃឈើនៅតែមានភាពខ្វះចន្លោះ និងបញ្ហាប្រឈមជាច្រើនដែលធ្វើឱ្យពាណិជ្ជកម្មអនុផលព្រៃឈើនៅកម្ពុជាមានការលំបាក និងទុកឱកាសនៃការរកប្រាក់ចំណូល ដែលជាវិភាគទានដល់សេចក្តីសុខ និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ស្ថិតនៅពីក្រោយប្រទេសជិតខាង រាប់ចាប់ពីច្រវាក់តម្លៃអនុផលព្រៃឈើ ដំណើរការច្នៃប្រឌិត ការភ្ជាប់ខ្លួនជាមួយផ្នែកឯកជន នីតិវិធីនាំចេញ សេវាកម្មរបស់មន្ត្រីរាជការពាក់ព័ន្ធនឹងទីផ្សារ, ការយកពន្ធ និង គោលនយោបាយគាំពារ។

ប្រទេសកម្ពុជាគឺជាប្រទេសមានសក្តានុពលក្នុងការបង្កើនប្រាក់ចំណូលបន្ថែមពី វិស័យអនុផលព្រៃឈើ ប៉ុន្តែវាកំពុងរង់ចាំប្រព័ន្ធមួយប្រកយដោយការជ្រោមជ្រែង (friendly) និងអាច

---

[2] សមាជិកសមាគមផ្កៅ (RAC) និងឫស្សី រយកប្រាក់បានជិត ២លានដុល្លារក្នុង១ឆ្នាំ។ យោងតាមលោក សុវណ្ណ ពិសិដ្ឋ នាយក RAC.

[3] UNDP៖ សេចក្តីសង្ខេបប្រតិបត្តិ នៃរបាយការណ៍ស្រាវជ្រាវរបស់ UNDP ស្តីអំពី ការបន្ថែមគុណតម្លៃ នៃអនុផលព្រៃឈើដើម្បីផលប្រយោជន៍ដែលបានបង្កើន ដល់ពលរដ្ឋជនបទ ២០០៧ ដោយ Emmanuelle Andaya និង ខូ អៀងហួត។

អនុវត្តបាន (practical) ដើម្បីឱ្យវិស័យនេះអាចសម្រេចបាន និង រួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា[4]។

ទំនាក់ទំនងរឹងមាំមួយបានផុសឡើងរវាងវិភាគទានរបស់អនុផលព្រៃឈើចំពោះប្រាក់ចំណូលក្នុងគ្រួសារ និងការធ្វើសមាហរណកម្មនៃគ្រួសារទៅក្នុងសេដ្ឋកិច្ចសាច់ប្រាក់ (Brian Belcher, ២០០៣, Manuel Ruiz-Perez Ramadhani Achdiawan ប្រទេសអាល្លឺម៉ង់) ។

ការស្រាវជ្រាវបានជួយដល់អ្នកពាក់ព័ន្ធរបស់អនុផលព្រៃឈើ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា និងសមាជិក ព្រមទាំងដៃគូនានាដូចជា NTFP-EP, WWF និង WCS ដោយមានការគាំទ្រពីគម្រោងផ្សេងៗដូចជា PaFF / SRJS, V4MF, MRLG, IKEA, SIDA, BfdW, Diakonia និង NPA ដល់ការឈ្វេងយល់ពីលទ្ធភាពនៃការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើដោយក្រុម CF និង CPA និងការគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់។ ការសិក្សាស្រាវជ្រាវមានគោលបំណង ៣ ដូចតទៅ៖

1. ដើម្បីកំណត់ពីឱកាសរបស់ CFs និង CPAs ក្នុងការកែលម្អជីវភាពរស់នៅ និងព្រៃឈើឱ្យមានការលូតលាស់ល្អតាមរយៈខ្សែច្រវាក់ផ្គត់ផ្គង់អនុផលព្រៃឈើ និងការបង្កលទ្ធភាពខាងបរិស្ថាន។

---

[4] ចំណុចនេះត្រូវបានលើកឡើងនៅក្នុងរបាយការណ៍ស្រាវជ្រាវ និងបទបង្ហាញរបស់អ្នកជំនាញជាច្រើនដូចជា៖ បទបង្ហាញស្ដីពីគោលនយោបាយពាណិជ្ជកម្មផ្ដៅកម្ពុជា, Tod Sigaty, ទីប្រឹក្សាគោលនយោបាយផ្ដៅអន្តរជាតិ, ២ មិថុនា ២០១១, WWF; របាយការណ៍ស្រាវជ្រាវរបស់ UNDP៖ សេចក្ដីសង្ខេបប្រតិបត្តិ នៃរបាយការណ៍ស្រាវជ្រាវរបស់ UNDP ស្ដីអំពី ការបន្ថែមគុណតម្លៃ នៃអនុផលព្រៃឈើដើម្បីផលប្រយោជន៍ដែលបានបង្កើន ដល់ពលរដ្ឋជនបទ ២០០៧ ដោយ Emmanuelle Andaya និង ខូ អៀងហួត។; WWF៖ ក្រុមការងារ ពង្រឹង គោលនយោបាយ និងពាណិជ្ជកម្មផ្ដៅ៖ "គម្រោងសាកល្បងអនុវត្តគោលនយោបាយ" រស់ សុដ្ឋា ឆ្នាំ២០១១ (គម្រោងនេះត្រូវបានធ្វើដោយសហការជាមួយមន្ត្រីបច្ចេកទេសជាន់ខ្ពស់ រដ្ឋបាលព្រៃឈើ/ ក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួង បរិស្ថាន និង និងក្រសួងពាណិជ្ជកម្ម) ។

2. ដើម្បីកំណត់បញ្ហាជាក់ស្តែងដែលសហគមន៍ CFs និង CPAs ដើម្បីធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ ហើយថាតើបញ្ហានេះប៉ះពាល់ទៅលើការគ្រប់គ្រងប្រកបដោយចីរភាពនៃ CFs និង CPAs យ៉ាងណា។ និង
3. ផ្តល់អនុសាសន៍ថាតើ ច្បាប់ពាក់ព័ន្ធនឹងអនុផលព្រៃឈើរួមទាំងការលើកលែងពន្ធអាចត្រូវបានកែលម្អយ៉ាងដូចម្តេច ដើម្បីអាចធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ និងការប្រើប្រាស់អនុផលព្រៃឈើដោយចីរភាពដោយ CFs និង CPAs។

## ២. ដំណើការ និងវិធីសាស្ត្រ

នេះជាការស្រាវជ្រាវបែបគុណភាព និងមានការចូលរួម ។ ការស្រាវជ្រាវ ផ្អែកលើ វិធីសាស្ត្រពីរ គឺសិក្សាលើឯកសារមានស្រាប់ និងការសម្ភាសន៍ ពាក់កណ្តាលផ្លូវការ ដោយមានការសម្ភាសបុគ្គលគន្លឹះ និង មានក្រុមពិភាក្សា (Focus Group Discussion) ។

មានឯកសារទិន្នន័យបន្ទាប់បន្សំពាក់ព័ន្ធមួយចំនួន ត្រូវបានពិគ្រោះតាមរយៈការសិក្សានូវឯកសារមានស្រាប់ មានដូចជា ច្បាប់ពាក់ព័ន្ធ គោលការណ៍ស្តីអំពីការនាំចេញ និងការធ្វើពាណិជ្ជកម្ម របាយការណ៍ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ឯកសាររដ្ឋបាល របាយការណ៍សិក្ខាសាលា និងវេទិកាថ្នាក់ជាតិស្តីអំពីអនុផលព្រៃឈើ និងរបាយការណ៍ស្រាវជ្រាវនានាដែលធ្វើកន្លងមក។ ឯកសារទាំងនោះត្រូវបានអាន និងសំយោគ។ *សូមមើលបញ្ជីឯកសារយោង (ទិន្នន័យបន្ទាប់បន្សំដែលបានពិគ្រោះ) នៅឧបសម្ព័ន្ធ ១ ។*

ចំពោះការសម្ភាសបុគ្គលគន្លឹះត្រូវបានធ្វើឡើងចំពោះថ្នាក់ដឹកនាំ CPAs/CFs ឈ្មួញកណ្តាលសហគ្រាស និងក្រុមហ៊ុនអនុផលព្រៃឈើ អង្គការអនុផលព្រៃឈើ និងបណ្តាញរបស់ពួកគេ អ្នកទិញសំខាន់ៗ និងមន្ត្រីនាយកដ្ឋានជាន់ខ្ពស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអង្គការគាំទ្រវិស័យអនុផលព្រៃឈើ ។ សរុបមានចំនួន ៤៣ នាក់ (ស្រី ១០ នាក់) ត្រូវបានសម្ភាស ។ *សូមស្វែងរកព័ត៌មានលម្អិតអំពីអ្នកត្រូវសម្ភាសនៅឧបសម្ព័ន្ធ ២ ។*

ក្រុមពិភាក្សាមានចំនួន ១០ ក្រុម ត្រូវបានធ្វើឡើងដោយ មានអ្នកចូលរួម ចំនួន ៩២ នាក់ (ស្រី ២៧ នាក់) មកពីសហគ្រាសអនុផលព្រៃឈើចំនួន ១០ ដែលមាន CF ចំនួន៦ CPA ចំនួន ៤ ដោយជួបជាលក្ខណៈប្រមូលផ្តុំ។ ពួកគេជាសមាជិកគណៈកម្មាធិការអនុផលព្រៃឈើ និងជាសមាជិក CF/CPAs ទាក់ទងនឹងប្រជាជននៅក្នុងសហគមន៍ដែលបានសម្ភាសក្នុងស្រុក[5]។ ផ្នែកអនុផលព្រៃឈើដែលត្រូវបានសម្ភាស គឺផ្តៅ/ឫស្សី ទឹកឃ្មុំ និងទ្រាំង។ ពួកគេត្រូវបានជ្រើសរើសដោយយោងតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

i. CFs និង CPAs ដែលត្រូវបានអនុញ្ញាតពីរដ្ឋបាលព្រៃឈើ/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។
ii. CFs និង CPAs បានទទួលការអនុម័តផែនការប្រមូលផលប្រកបដោយចីរភាព ពីរដ្ឋបាលព្រៃឈើ / ក្រសួងបរិស្ថានផងដែរ ។
iii. CFs/CPAs កំពុងដំណើរការពាណិជ្ជកម្ម NTFP។
iv. ការពិចារណាលើកត្តាភូមិសាស្ត្រ និងតាមវិស័យ; និង
v. តំបន់ដែលអាចចេញចូលបានស្របតាមពេលវេលាកំណត់។

យោងតាមលក្ខណៈវិនិច្ឆ័យខាងលើ សហគ្រាសឫស្សី/ផ្តៅចំនួន២ (មាន CF ៨) នៅក្នុងខេត្តកំពត សហគ្រាសទឹកឃ្មុំ និងឫស្សី១ នៅកោះកុង (មាន CPA២) សហគ្រាស ទឹកឃ្មុំ និងទ្រាំង ២នៅក្នុងខេត្តព្រះវិហារ (មាន CF៣ និង CPA១) និងសហគ្រាសទឹកឃ្មុំ និងឫស្សី៣ នៅមណ្ឌលគិរី (សុទ្ធតែ CPA ទាំងអស់) ត្រូវបានជ្រើសរើស និងពិភាក្សាជាមួយ ។

ជាមធ្យម មានមនុស្ស ១០ នាក់ក្នុងមួយក្រុមបានចូលរួមក្នុងក្រុមពិភាក្សា ក្នុង១កន្លែងៗ។ *សូមស្វែងរកបញ្ជីលម្អិតនៃអ្នកចូលរួមនៅឧបសម្ព័ន្ធ ៣។*

---

[5] សមាជិកសហគ្រាស NTFP ឬសមាជិកគណៈកម្មាធិការ NTFP ក៏ជាសមាជិកនៃ CFs / CPAs ផងដែរ។ ពួកគេត្រូវបានបង្កើតឡើងពី CF / CPAs ។ ជាលម្អិត មាន CFs 11 និង CPAs 4។ ការពិភាក្សាក្រុមផ្តោតនៅ CF ដើមដូងមាន CF ៦ ដែលនៅជុំវិញបានចូលរួមជាមួយគ្នា ហើយនៅក្នុងការពិភាក្សាក្រុមផ្តោតនៅព្រៃខ្មៅ មានការចូលរួមពីដំណាក់វល្លស ទាំងពីរនេះស្ថិតនៅក្នុងខេត្តកំពត។

កម្រងសំណួរណែនាំត្រូវបានប្រើសម្រាប់ការពិភាក្សា។ កិច្ចពិភាក្សាត្រូវបានផ្តោតលើការកំណត់ឱកាសនៃ CFs និងCPAs ដើម្បីលើកកម្ពស់មុខរបររស់នៅ និងការលូតលាស់ព្រៃឈើតាមរយៈច្រវាក់អនុផលព្រៃឈើ និងការបង្កលក្ខណៈដល់បរិស្ថាន។ បញ្ហាជាក់ស្តែង ដែល CFs និង CPAs ប្រឈមក្នុងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ និងរបៀប ដែលវាជះឥទ្ធិពលដល់ការគ្រប់គ្រង CFs និង CPAs ប្រកបដោយនិរន្តរភាព ការប្រមូល និងការទទួលយកនូវអនុសាសន៍របស់ពួកគេ ថាតើ ច្បាប់ទាក់ទងនឹងអនុផលព្រៃឈើ រួមទាំងការលើកលែងពន្ធអាចត្រូវបានធ្វើ ឱ្យប្រសើរឡើងយ៉ាងណា ដើម្បីពាណិជ្ជូបនីយកម្មអនុផលព្រៃឈើ និងការប្រើ ប្រាស់អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ដោយ CFs និង CPAs។

## ជំហាននៃការស្រាវជ្រាវ ៖

ដំណើរការនៃការស្រាវជ្រាវត្រូវបានអនុវត្តតាម ៨ ជំហានដូចខាងក្រោម៖

1. ផែនការសិក្សាស្រាវជ្រាវ
2. សិក្សាលើឯកសារមានស្រាប់
3. ការសម្ភាស/ប្រមូលទិន្នន័យបឋម
4. វិភាគ និងព្រាងរបាយការណ៍
5. ប្រឹក្សាយោបល់ជាមួយអ្នកជំនាញអនុផលព្រៃឈើ
6. ការធ្វើការបង្ហាញដល់ក្រុមការងារ NGOF និងភាគីពាក់ព័ន្ធដើម្បីទទួលបានមតិយោបល់ និងការពិភាក្សា និង
7. កែសម្រួល និងបញ្ចប់

## វិធីសាស្ត្រវិភាគទិន្នន័យ ៖

ការរៀបចំព័ត៌មានទូទៅ ៖ ទិន្នន័យដែលប្រមូលបានត្រូវបានសំយោគ និងបូកសរុបដោយយោងលើចំណុចរួម និងប្រើប្រាស់ភស្តុតាងដែលអាចផ្ទៀងផ្ទាត់បាន ដូចជាទិន្នន័យ សេចក្តីដកស្រង់ កំណត់ត្រា (ដំណើរការ) ជាដើមដើម្បីគាំទ្រ របាយការណ៍។ ការរកឃើញត្រូវបានរៀបចំទៅតាមគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ។

ក្រាហ្វិច ៖ ក្រាហ្វិចត្រូវបានប្រើដើម្បីបង្ហាញសេចក្តីសន្និដ្ឋាននៃព័ត៌មាន អំពីឱកាសសម្រាប់ការកែលម្អអាជីវកម្មចិញ្ចឹមជីវិតទាក់ទងនឹងអនុផលព្រៃឈើ។ ការរៀបចំ ឬការបង្ហាញព័ត៌មាន

ចាប់ផ្តើមពីសហគ្រាសអនុផលព្រៃឈើកម្ពុជា ដល់ឧបសគ្គរួម និងឧបសគ្គផ្សេងៗនៃទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ហើយបន្ទាប់មកឱកាសទីផ្សាររួម និងឱកាសទីផ្សារដោយឡែក ពោលគឺ ទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ការរៀបចំដូច្នេះគឺដើម្បីជួយអ្នកអានឱ្យងាយយល់ពីព័ត៌មានស្មុគស្មាញស្តីពីអនុផលព្រៃឈើទាំងក្នុងទីផ្សារក្នុងស្រុក និងអន្តរជាតិតាមរយៈការពន្យល់ជារូបភាព។ ឧបករណ៍ដើមឈើបញ្ហាក៏ត្រូវបានប្រើដើម្បីរៀបចំព័ត៌មានវិភាគអំពីបញ្ហាចម្បងនៃការធ្វើពាណិជ្ជកម្មរបស់អនុផលព្រៃឈើ បុព្វហេតុ និងផលប៉ះពាល់នៃបញ្ហា ដល់និរន្តរភាពនៃព្រៃឈើ។ វាជួយសម្រួលដល់អ្នកអានឲ្យកាន់តែងាយមើល និងយល់យ៉ាងឆាប់រហ័សពីការពិពណ៌នាបញ្ហា តាមរបៀបរូបភាព។

មុនពេលធ្វើការបង្ហាញដល់ NGOF ឬអ្នកពាក់ព័ន្ធដើម្បីផ្តល់យោបល់ អ្នកស្រាវជ្រាវបានប្រឹក្សាជាមួយអ្នកជំនាញអនុផលព្រៃឈើសំខាន់ៗចំនួនបីនាក់រួមមាន៖ លោក Richard Dansey, CEO នៃ LEOPA BAMBOO, លោកឡុង រតនៈកុមារ អនុប្រធាននាយកដ្ឋានសហគមន៍ព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង លោកជ័យ គូឡង់ WWF ក្នុងគោលបំណងដើម្បីកែតម្រូវនូវការរកឃើញឲ្យបានត្រឹមត្រូវជាពិសេសចំណុចសំខាន់ និងនៅមិនទាន់ច្បាស់នៃការសិក្សាស្រាវជ្រាវតាមរយៈការដេញដោលគ្នា និងការវិភាគ។ ការធ្វើបែបនេះបានជួយធានាការវិភាគភាគច្រើនពិតជាត្រឹមត្រូវ និងគ្មានកំហុស។

## ៣. វិសាលភាព និងការកំណត់ ៖

ការសិក្សាស្រាវជ្រាវត្រូវបានផ្តោតតែទៅលើពាណិជ្ជកម្មអនុផលព្រៃឈើដែលគ្រប់គ្រងដោយ CFs និង CPAs ដែលត្រូវបានគេហៅថា សហគ្រាសអនុផលព្រៃឈើ ពោលគឺសហគ្រាសឫស្សី/ផ្តៅ ទឹកឃ្មុំ និងសហគ្រាសជ័រ ។ ដូចដែលបានរាយការណ៍ ខាងលើខេត្តចំនួន ៤ ត្រូវបានជ្រើសរើសដើម្បីធ្វើការប្រមូល ទិន្នន័យបឋម។ ពួកគេត្រូវបានជ្រើសរើស ក្នុងចំណោមខេត្តដែលមានអនុផលព្រៃឈើ ដែលកំពុងធ្វើពាណិជ្ជកម្ម ។

ការស្រាវជ្រាវនេះនឹងមិនអាចតំណាងឱ្យព័ត៌មានជាតិ អំពីប្រធានបទនេះ បានទូលំទូលាយទេដោយសារពេលវេលា និងថវិកាមានការកំណត់។ ទោះយ៉ាងណាក៏ដោយ វាផ្តល់ព័ត៌មានជាមូលដ្ឋានអំពីប្រធានបទ ជាពិសេស ជាព័ត៌មានរួមស្តីអំពីការសិក្សាពីលទ្ធភាពទូទៅក្នុង

ចំណោមសហគមន៍អនុផលព្រៃឈើ និងអ្នកពាក់ព័ន្ធនឹងអនុផលព្រៃឈើក្នុងប្រទេសកម្ពុជា ដែលអនុវត្តជាក់ស្តែងសម្រាប់គោលបំណងអភិវឌ្ឍន៍វិស័យនេះ។ លើសពីនេះទៀត វាជាមូលដ្ឋាន ឬជាឯកសារយោងសម្រាប់ការពិភាក្សា ក៏ដូចជាសម្រាប់ធ្វើការផ្ទៀងផ្ទាត់បន្ថែមទៀតនៅពេល ដែលត្រូវការសម្រាប់គោលបំណងស្រាវជ្រាវ។

# ការរកឃើញ

## ១. ស្ថានភាពទូទៅនៃក្របខណ្ឌគោលនយោបាយថ្នាក់ជាតិទាក់ទងនឹងអនុផលព្រៃឈើ

នៅព្រះរាជាណាចក្រកម្ពុជាមានច្បាប់ចំនួនពីរដែលធានាបាននូវការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើ និងជីវចម្រុះប្រកបដោយនិរន្តរភាព គឺច្បាប់ស្តីពីព្រៃឈើ (២០០២) និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨)។ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ដែលផ្តល់ការណែនាំសម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើកម្មវិធីព្រៃឈើជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១០-២០២៩ រាជរដ្ឋាភិបាលមានបេសកកម្មជំរុញការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើប្រកបដោយចីរភាព ដើម្បីជាវិភាគទានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់អាជីវកម្មចិញ្ចឹមជីវិត កំណើនសេដ្ឋកិច្ច និងការការពារបរិស្ថាន រួមទាំងអភិរក្សជីវចម្រុះ និងបេតិកភណ្ឌវប្បធម៌។

លើសពីនេះទៀត ច្បាប់ដ៏សំខាន់ទាំងពីរខាងលើគឺច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិកំពុងត្រូវបានរៀបចំធ្វើវិសោធនកម្មដើម្បីលុបបំបាត់បទឧក្រិដ្ឋព្រៃឈើ ដែលត្រូវបានប្រព្រឹត្តដែលមិនអាចគ្រប់គ្រងបាន និងផ្តល់សិទ្ធិកាន់តែច្រើនដល់សហគមន៍ក្នុងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។ ជាជាក់លាក់ច្បាប់ព្រៃឈើនឹងត្រូវធ្វើវិសោធនកម្មក្នុងឆ្នាំ ២០២៣[6] ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិក៏កំពុងត្រូវបានរៀបចំដាក់ស្នើសុំធ្វើវិសោធនកម្មដែរ តែកាលកំណត់នៅមិនទាន់ដាក់ចេញ។

---

[6] សារព័ត៌មាន ខ្មែរថៃម៖ ការធ្វើវិសោធនកម្មច្បាប់ព្រៃឈើនឹងត្រូវធ្វើមុនឆ្នាំ ២០២៣ ចុះផ្សាយថ្ងៃទី ២៦ កញ្ញា ២០១៨

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាគោលនយោបាយធ្វើឲ្យសម្រេចបានសហគ្រាសព្រៃសហគមន៍ដោយនិរន្តរភាព សម្រាប់ការដោះស្រាយសេចក្តីត្រូវការរបស់ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ព្រៃ។ ក្រមបរិស្ថាន និងធនធានធម្មជាតិនៃប្រទេសកម្ពុជាក៏នឹងផ្តល់នូវក្របខណ្ឌបន្ថែមទៀត ដោយមានគោលបំណងជួយបង្កលក្ខណៈដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារធនធានធម្មជាតិ និងធនធានវប្បធម៌ឡើងវិញ។ ក្រៅពីនោះ ច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសពាណិជ្ជកម្ម និងសិប្បកម្ម និងកម្មសិទ្ធិបញ្ញាផ្តល់កម្រិតគាំទ្រអប្បបរមាសម្រាប់សហគ្រាសព្រៃឈើ (NTFP-EP)[7] ។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថានបានប្តេជ្ញាថានឹងធ្វើការដើម្បីអនុវត្តគោលនយោបាយស្តីពីការប្រើប្រាស់ និងផលិតកម្ម និងការដាក់ស្លាកអេកូ ដែលមានគោលដៅប្រើប្រាស់ដើម្បីលើកកម្ពស់ការអភិវឌ្ឍអនុផលព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ការដាក់ស្លាកអេកូនឹងជូនដំណឹងដល់អ្នកទិញអំពីប្រភពផលិតកម្ម វិធីសាស្ត្រនៃផលិតកម្ម និងការចូលរួមផលិតដែលមានទំនាក់ទំនងជាមួយការអភិរក្សធនធានធម្មជាតិ[8].

សរុបសេចក្តីមកព្រះរាជាណាចក្រកម្ពុជាមានគោលនយោបាយជាតិជាក់លាក់មួយចំនួនដែលជំរុញការធ្វើពាណិជ្ជកម្ម និងការច្នៃប្រឌិតធនធានព្រៃឈើ ព្រមទាំងនិរន្តរភាពព្រៃឈើ។ ក្រៅពីនេះមានចន្លោះប្រហោងសំខាន់ៗមួយចំនួនដូចជាមិនមានសេចក្តីណែនាំពិស្តារសម្រាប់ CFs/CPAs ដើម្បីស្នើសុំរួចពន្ធលើការប្រមូលផលអនុផលព្រៃឈើ។ កង្វះគោលការណ៍ណែនាំសម្រាប់ការដឹកជញ្ជូនអនុផលព្រៃឈើ និងការបង្កើតសហគ្រាសអនុផលព្រៃឈើ។

---

[7] ការប៉ាន់ប្រមាណស្តីអំពីគោលនយោបាយអនុផលព្រៃឈើចំពោះផលិតផលអនុផលព្រៃឈើ ដោយ Edna Maguigat 2020។

[8] NTFP-EP, WWF, Fintrac: កំណត់ហេតុវេទិការថ្នាក់ជាតិលើកទី១នៃសហគ្រាសអនុផលព្រៃឈើសហគមន៍ កថាខណ្ឌចុងក្រោយនៃទំពរទី១៥ ខែឧសភា ២០១៥។

ជាមួយនេះដែរ ច្បាប់ក៏មិនទាន់បានពិពណ៌នាច្បាស់លាស់អំពីសិទ្ធិរបស់ CFs/CPAs ក្នុងការដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារនៅឡើយ ការកំណត់លើរយៈពេលនៃការគ្រប់គ្រង CFs/CPAs ដែលទទួលបានការអនុញ្ញាតគឺម្តងៗបានត្រឹមតែ១៥ ឆ្នាំប៉ុណ្ណោះហើយ CFs/CPAs មិនមានសិទ្ធិធ្វើកិច្ចសន្យាជាមួយវិនិយោគិន ឯកជនដើម្បីអភិវឌ្ឍ និងកែលម្អព្រៃឈើដើម្បីគោលបំណងអភិវឌ្ឍន៍ជីវភាពរបស់ពួកគេផងដែរ[9] ។



[9] CF/CPAs ទទួលបានរយៈពេល១៥ឆ្នាំដើម្បីចាត់ចែងសហគមន៍របស់ខ្លួនដែលបានអនុញ្ញាត។ វាជាកម្មវត្ថុដើម្បីអនុញ្ញាតជាថ្មី បន្ទាប់ពីការវាយតម្លៃជាផ្លូវការ និងថាតើអាចបន្ត ឬ មិនបន្តដល់សហគមន៍ដែលស្នើសុំ។ បញ្ហានេះក៏បានមើលឃើញដូចគ្នាដោយ នាយដ្ឋានជីវភាព នៃក្រសួងបរិស្ថាន តាមរយៈរបាយការណ៍ស្តីពីការពិនិត្យនិងសិក្សាច្បាប់តំបន់ការពារធម្មជាតិដើម្បីកែសម្រួលការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (CPA) និងអនុញ្ញាតឲ្យសហគមន៍ដឹកជញ្ជូនអនុផលព្រៃឈើ ដែលរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ ដើម្បីស្នើសុំឲ្យមានការកែលម្អគោលនយោបាយ។ សហគមន៍មិនអាចផ្ទេរសហគមន៍ព្រៃឈើ ឬសហគមន៍តំបន់ការពារធម្មជាតិដែលផ្តល់ឲ្យដោយរដ្ឋទៅឲ្យភាគីទី៣បានឡើយ (មាត្រា៤៤ នៃច្បាប់ព្រៃឈើ និងមាត្រា ២៦ នៃច្បាប់ស្តីអំពីតំបន់ការពារ)។

## ២. ឱកាសនៃ CF/CPA ដើម្បីកែប្រែអាជីវកម្មចិញ្ចឹមជីវិត និងការលូតលាស់ព្រៃឈើ តាមរយៈច្រវាក់ផ្គត់ផ្គង់ និងការបង្កលក្ខណៈ ដល់បរិស្ថាន

**ទីផ្សារក្នុងស្រុក**

**ទីផ្សារអន្តរជាតិ និងការវិនិយោគ**

**b) ឱកាសទីផ្សារក្នុងស្រុក**

អ្នកទិញដែលជាអ្នកមាន និងថ្នាក់កណ្តាល កំពុងកើនឡើងនិងគាំទ្រជាបន្តក្នុងកម្រិតតូចសម្រាប់ការប្រើប្រាស់ និងអាជីវកម្ម៖

- សហគ្រាសកែច្នៃអនុផលព្រៃឈើ សំដៅលើ (ឈ្មួញកណ្តាលនៃការកែច្នៃ និងពាណិជ្ជកម្ម)
- **អតិថិជនជាបុគ្គល** (អ្នកមានអាជីវកម្មកំសាន្តឬអេកូទេសចរនានា)
- ជនបរទេសស្នាក់នៅក្នុងប្រទេសកម្ពុជា និងខ្មែរអ្នកមាន និងជីវភាពមធ្យម

**c) ឱកាសទីផ្សារអន្តរជាតិ**

អ្នកទិញកម្រិតយក្សដែលទិញច្រើនមហិមា និងយូរអង្វែង (រាប់រយតោន ឬ ច្រើនពាន់ឯកតាដើម្បីនាំចេញ) មាន LEOPA BAMBOO (នៅខ្មែរ), For Front (នៅខ្មែរសហការជាមួយប្រទេសអាមេរិក, Bamboo Surfboard), Bamcore (US), IKEAs (international), Tikamoon (អង់គ្លេស)

**a) ឱកាសរួម**

- អនុផលព្រៃឈើមានគុណភាព និងមានទីផ្សារដែលមានសក្តានុពល អាចទទួលបានថ្លៃសួយសារ និងបុព្វលាភមិនគិតថ្លៃ ឬ តម្លៃទាប និងការលើកលែងពន្ធគយកម្រិតសូន្យ ឬ កម្រិតទាប
- ការយល់ដឹងអំពីបរិស្ថាន និងការចង់បាន ឬតម្រូវការថ្មី

**ឧបសគ្គបច្ចុប្បន្ននៃទីផ្សារក្នុងស្រុក**

- យុទ្ធសាស្ត្រទីផ្សារមានកំណត់
- ការប្រកួតប្រជែងជាមួយឈ្មួញកណ្តាលជាបុគ្គល (ផ្តៅ ទឹកឃ្មុំក/ទ្រាំង)

**ឧបសគ្គបច្ចុប្បន្ននៃទីផ្សារអន្តរជាតិ**

- ខ្វះបទពិសោធន៍នាំចេញៈ
- ភាពជាអ្នកដឹកនាំមានកំណត់ជាមួយក្រសួងពាក់ព័ន្ធ និងរវាងក្រសួង និងសហគ្រាស/ក្រុមហ៊ុន

**របាំងទីផ្សារក្នុងនិងក្រៅប្រទេសរួម**

- កង្វះចំណង់ចំណូលចិត្តផ្ទាល់ខ្លួន / ភាពជាសហគ្រិននិងឧត្តមានុវត្ត
- ជំនាញបច្ចេកទេសទាប / អន់
- ឧបករណ៍កែច្នៃ / ម៉ាស៊ីនមានកំណត់
- កង្វះដើមទុន
- នីតិវិធីនាំចេញដ៏ស្មុគស្មាញ វែងនិងការអនុវត្តខុសៗគ្នា (មើលបន្ថែមនៅឧបសម្ព័ន្ធ ៥ ស្តីពីដំណើរជាក់ស្តែង)
- ថ្លៃសេវាក្រៅផ្លូវការ (ចំណាយខ្ពស់ / អាជីវកម្មមិនស្អាត)
- គុណភាពផលិតផលអន់
- វត្ថុធាតុដើមមិនគ្រប់គ្រាន់ (ផ្តៅទឹកឃ្មុំរនាំង / ទ្រាំង)

**សហគ្រាសអនុផលព្រៃឈើក្នុងប្រទេសកម្ពុជា**

*ក្រាហ្វិចទី១៖ ការពន្យល់ និងវិភាគអំពីឱកាសនិងឧបសគ្គនៃទីផ្សារក្នុងស្រុកនិងអន្តរជាតិនៃផលិតផលអនុផលព្រៃឈើកម្ពុជា*

CF/CPAs មានឱកាសល្អជាច្រើនដែលអាចឱ្យពួកគេធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងភាពលូតលាស់នៃព្រៃឈើតាមរយៈច្រវាក់ផ្គត់ផ្គង់ពាណិជ្ជកម្ម និងការបង្កលក្ខណៈបរិស្ថានដោយសារហេតុផលជាច្រើន។ ឱកាសទាំងនោះត្រូវបានបែងចែកជា ៣ ប្រភេទ៖ ក) ឱកាសរួម (សម្រាប់ទីផ្សារក្នុងស្រុក និងអន្តរជាតិ) ខ) ឱកាសទីផ្សារក្នុងស្រុក និងគ) ឱកាសទីផ្សារអន្តរជាតិ៖

## ក) ឱកាសទីផ្សាររួម៖

> នៅបណ្តាប្រទេសសហភាពអឺរ៉ុបប្រជាជនចូលចិត្តឈើច្នៃពីឫស្សី សម្រាប់តម្រូវការលំនៅដ្ឋានរបស់ពួកគេ និងផលិតផលជាច្រើនទៀត ដែលធ្វើពីក្រដាសសសៃ ព្រោះឫស្សីស្អាត និងលូត លាស់លឿន។ នោះហើយ ជាមូលហេតុដែល មានក្រុមហ៊ុន ឈើជាច្រើនចង់ វិនិយោគនិងកែច្នៃឈើពីឫស្សី។ នៅប្រទេស កម្ពុជា មានដើម ឫស្សីយ៉ាងច្រើននៅតាមដងទន្លេមេគង្គ នៅ តំបន់ ខ្ពង់រាបពោលគឺខេត្តស្ទឹងត្រែង ដែលខ្ញុំបានសាងសង់រោងចក្រកែច្នៃឫស្សីរបស់ខ្ញុំនៅទីនោះ។ *លោក Richard Dansy នាយកប្រតិបត្តិនៃ LEOPA BAMBOO ។*

i. មានអនុផលព្រៃឈើមួយចំនួនធំមានគុណភាពនិងមានតម្លៃនិងឈានមុខគេពិសេសទឹកឃ្មុំព្រៃ ជ័រទឹកផ្តៅ និងទ្រាំង។ អនុផលទាំងនេះមានសក្តានុពលនិងអាចលក់បានទាំងនៅទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ឫស្សីត្រូវបានមើលឃើញថាជាវត្ថុធាតុដើមពាណិជ្ជកម្មប្រកបដោយចីរភាព និងសក្តានុពលមួយដែលកំពុងត្រូវបានប្រើប្រាស់ ឬកែច្នៃសម្រាប់វត្ថុធាតុដើមជាច្រើនដែលពិភពលោកកំពុងប្រើប្រាស់កាន់តែខ្លាំងឡើងៗ ជារៀងរាល់ថ្ងៃ ដូចជាសម្រាប់សម្ភារៈគេហដ្ឋាន ពពួកកន្ត្រក គ្រឿងសង្ហារិម ក្រដាសអនាម័យ។ ក្រដាស (ក្រដាស់ជូតមាត់..) វត្ថុសម្រាប់ទុកដាក់ផ្សេងៗ និងឈើច្នៃសម្រាប់លំនៅដ្ឋានដូចជាកម្រាល

ជញ្ជាំង ឈើបាទទម្រ ។ល។ ក្រៅពីសម្រស់របស់វា ឫស្សីក៏ជារុក្ខជាតិសំខាន់សម្រាប់បរិស្ថាន[10].

តាមការប៉ាន់ស្មានប្រទេសកម្ពុជាអាចរកចំណូលបានដល់ទៅ ៥០ លានដុល្លារក្នុងមួយឆ្នាំដែលទទួលបានពីឫស្សី/ផ្តៅ ទឹកឃ្មុំ និងជ័រពីទីផ្សារក្នុងស្រុក និងអន្តរជាតិ ដោយផ្អែកលើទិន្នន័យរបាយការណ៍ និងលក្ខខណ្ឌខាងក្រោម៖

ផ្តៅ/ឫស្សី៖ ផ្អែកលើរបាយការណ៍ស្រាវជ្រាវថ្មីៗនេះ របស់UNDP[11] ជាមួយនឹងសមត្ថភាពកាន់តែប្រសើរ និងយុទ្ធសាស្ត្រនាំចេញ ប្រទេសកម្ពុជាអាចកំណត់យកចំណែកយ៉ាងហោចណាស់ ១,៥% នៃចំណែកឫស្សីត្បាញចំនួន ៤៧៦ លានដុល្លារស្មើនឹង ៧,១៧ លានដុល្លារ។ ចំណែក ៥ ភាគរយនៃតម្រូវការជីចំនួន ៦១៧.០០០ តោននៅកម្ពុជា។ តាមប៉ាន់ប្រមាណ វារួមចំណែកដល់ ១,៥ លានដុល្លារអាមេរិក។ ដើមឫស្សីមានតម្លៃ ០,៦ លានដុល្លារសម្រាប់ទីផ្សារក្នុងស្រុក។

ទីផ្សារពិភពលោកសម្រាប់កៅអីឫស្សី / ផ្តៅមានតម្លៃ ១៦៧ លានដុល្លារ។ ប្រសិនចាប់យកបាន ២% គឺមានតម្លៃស្មើ ៣,៣ លានដុល្លារ។ ប្រទេសវៀតណាមបាននាំផ្តៅចំនួន ៣៣,០០០ តោន ដើម្បីឆ្លើយតបនឹងតម្រូវការផលិតកម្មពាក់កណ្តាលសម្រេច។ ឆ្លៀតយកប្រយោជន៍នេះ ប្រសិនបើកម្ពុជាអាចចាប់បានយ៉ាងហោចណាស់ត្រឹម ២៥% នៃតម្រូវការនេះ វាអាចចូលរួមចំណែកដល់ ៧,៨ លានដុល្លារ។

---

[10] ឫស្សីជាសមាភាពសំខាន់មួយក្នុងការធ្វើឲ្យមានតុល្យភាពអ៊ុកស៊ីសែន និងកាបូនឌីអុកស៊ីតនៅក្នុងបរិយាកាស។ ព្រៃឫស្សីបញ្ចេញអុកស៊ីសែនច្រើនជាង ៣៥% ច្រើនជាងដើមឈើ។ ដោយហេតុផលនេះ ការដាំឫស្សីគឺជាមធ្យោបាយដ៏ល្អមួយដើម្បីកាត់បន្ថយការបំភាយកាបូនរបស់មនុស្ស និងជួយទប់នឹងកំដៅផែនដី ហើយពួកវាល្អណាស់សម្រាប់ការពារការហូរច្រោះបាក់ដី (Tewis Bamboo )។

[11] សេចក្តីសង្ខេបប្រតិបត្តិ នៃរបាយការណ៍ស្រាវជ្រាវរបស់ UNDP ស្តីអំពី ការបន្ថែមតម្លៃបនៃអនុផលព្រៃឈើដើម្បីផលប្រយោជន៍ដែលបានបង្កើនដល់ពលរដ្ឋជនបទ ២០០៧ ដោយ Emmanuelle Andaya និង ខូ អៀងហួត។

ដូចដែលបានពិភាក្សាខាងលើតម្រូវការ និងការចង់បាន (demand) ផលិតផលឫស្សី គឺមានច្រើនខុសៗគ្នា និងរឹងមាំ ឧទាហរណ៍ដូចជា ផ្ទះកំសាន្ត ឈើថ្មែជាដើម នឹងអាច បង្កើតចំណូលឲ្យសហគមន៍កាន់តែជុំកំភួន និងមាននិរន្តរភាពសម្រាប់ទាំងអាជីវកម្ម និងធនធានព្រៃឈើ។

ទឹកឃ្មុំ៖ ការធ្វើពាណិជ្ជកម្មទឹកឃ្មុំព្រៃបច្ចុប្បន្ននេះឆ្លើយតបបានតែ ភាគរយ តូចនៃ តម្រូវការតែប៉ុណ្ណោះ។ ទីផ្សារជាតិសរុបត្រូវបានប៉ាន់ប្រមាណ ថាមានចំនួន ៥០០ តោនក្នុងមួយឆ្នាំស្មើនឹង ៣,២ លានដុល្លារក្នុងមួយឆ្នាំ។ ទីផ្សារក្នុងតំបន់នៃអាស៊ីបូព៌ា/ អាស៊ីអាគ្នេយ៍មានតម្លៃ ២២៥ដុល្លារអាមេរិក។ ដោយពិចារណាលើផលិតកម្មហើយ កំណត់ទិសដៅតែ ២ ភាគរយនៃទីផ្សារក្នុងតំបន់នេះអាចចូលរួមវិភាគទានយ៉ាង ហោចណាស់ ២,២៥ លានដុល្លារអាមេរិក។

ជ័រទឹក៖ ការធានា និងការប្រមូលផ្តុំការផ្គត់ផ្គង់ និងការពង្រីកទីផ្សារអាចទទួលបាន អត្ថប្រយោជន៍ពីជ័រ ហើយស្វែងរកទីផ្សារផ្សេងទៀត សម្រាប់ផលិតកម្មដែលប៉ាន់ ប្រមាណពី ១៨.០០០ ទៅ ៣០.០០០ តោនអាចចូលរួមវិភាគទានយ៉ាងហោច ណាស់ ១៨ ទៅ ២៤ លានដុល្លារក្នុងមួយឆ្នាំដល់ជីវភាពរស់នៅ នៅតាមជនបទ។

ii. ការលើកលែងពន្ធ៖ ទាំង MAFF/FA និងក្រសួងបរិស្ថាន មានឆន្ទៈនិងត្រៀមខ្លួនផ្តល់ ការលើកលែងថ្លៃសួយសារ និងបុព្វលាភដល់ CF/CPAs លើការប្រមូលអនុផលព្រៃ ឈើដូចជាផ្តៅ និងឫស្សីដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ យោងតាម បទសម្ភាសន៍បុគ្គលគន្លឹះជាមន្ត្រីជាន់ខ្ពស់រដ្ឋបាលព្រៃឈើ/ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងនាយកដ្ឋានជីវភាពសហគមន៍នៃក្រសួងបរិស្ថាន។ ចំណុច នេះត្រូវបានអនុវត្តស្របតាមមាត្រា៥៣ នៃច្បាប់ស្តីពីព្រៃឈើ។ ក្រសួងធ្លាប់បានផ្តល់ ការអនុគ្រោះពន្ធមួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះរួចទៅហើយ។ ផ្អែក លើបទសម្ភាសន៍ នាយកដ្ឋានបច្ចេកទេសនៃរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន នាយកដ្ឋានត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើអន្តរាគមន៍ឬ ជួយនៅពេលណាដែលពួក គេទទួលបានសំណើសុំលើកលែងពន្ធ។ អ្វីដែលជាដំណឹងល្អនោះគឺថាមានការលើក

លែងពន្ធគយជាច្រើនលើការនាំចេញអនុផលព្រៃឈើ ជាពិសេសផលិតផលកែច្នៃអនុផលព្រៃឈើ។ សូមមើលតារាងខាងក្រោមដែលអ្នកស្រាវជ្រាវបានប្រមូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករលើអនុផលព្រៃឈើដែលពាក់ព័ន្ធ៖

| លរ | ប្រភេទនៃធនធានអនុផលព្រៃឈើ ឬផលិតផល | ពន្ធគយ |
|---|---|---|
| 1 | ឫស្សី និងផ្តៅស្រស់ (ឆៅ) | 10% |
| 2 | គ្រឿងសង្ហារិមធ្វើពីឫស្សី ឬផ្តៅ (ដូចជាតុ ទូដាក់ខោអាវ) | 5% |
| 3 | សម្ភារៈដាក់លើតុ ដូចជាចង្កឹះ ស្លាបព្រា ចាន វែក ជ្រុញ ។ល។ ធ្វើអំពីអនុផលព្រៃឈើ | 5% |
| 4 | កន្ត្រក និងកៅអីធ្វើអំពីឫស្សី ឬ ផ្តៅ | 0% |
| 5 | ទឹកឃ្មុំ | 0% |
| 6 | ជ័រទឹក | 0% |

ព័ត៌មាននេះអាចយកចេញបានពីគេហទំព័ររបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករឬ តំឡើង Apps ពន្ធគយឆ្នាំ ២០១៧ ដាក់ក្នុងទូរស័ព្ទវៃឆ្លាតដើម្បីយកព័ត៌មាន ឬអាន។

iii. ការយល់ដឹងអំពីបរិស្ថាន និងតម្រូវការ/ការចង់បានថ្មី៖ ប្រជាពលរដ្ឋក្នុងពិភពលោកចាប់ផ្តើមព្រួយបារម្ភអំពីបញ្ហាបរិស្ថានដូចជាការប្រែប្រួលអាកាសធាតុ សារៈសំខាន់នៃព្រៃឈើចំពោះប្រព័ន្ធអេកូឡូស៊ី ភាពរេចរឹលនៃធនធានព្រៃឈើ។ល។ មនុស្ស ឬក្រុមហ៊ុនចង់ប្រើប្រាស់ ឬផលិតផលិតផលបែបថ្មីជំនួសឲ្យផលិតផលឈើដែលវាជួយរក្សាបរិស្ថានប្រកបដោយនិរន្តរភាព។ លើសពីនេះទៀត ពួកគេចង់ប្រើអ្វីដែលថ្មីប្លែក និងស្រស់ស្អាតជាមួយនឹងគំនិតច្នៃប្រឌិតជាពិសេសអ្វីៗ ដែលមិនធ្លាប់មានពីមុនមក។

iv. មានក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិកាន់តែច្រើនឡើងដែលចង់ចុះកិច្ចសន្យាជាមួយ CF/CPAs ដើម្បីដាំដើមឈើ និងផ្លែឈើឧស្សាហកម្ម។ ដើមឈើឧស្សាហកម្មទាំងនោះ អាចជាអាកាស្យា ដើមខ្លឹមចន្ទន៍ កាកាវ (សម្រាប់ផលិតសូកូឡា) ហើយពួកគេបានផ្តល់នូវប្រាក់ចំណូលរហូតដល់ទៅរាប់លានដុល្លារក្នុងមួយឆ្នាំដែល លើកកម្ពស់

ជីវភាពរស់នៅរបស់សហគមន៍ និងធានានិរន្តរភាពព្រៃឈើក្នុងរយៈពេលយូរតាមការចង់បាន។ ឧទាហរណ៍ សហគមន៍ CPA តាសាល់ នៅតំបន់សត្វព្រៃភ្នំឱរ៉ាល់ក្នុងខេត្តកំពង់ស្ពឺបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន ២ លើកគឺទី ១ នៅឆ្នាំ ២០១៨ និងលើកទី ២ នៅឆ្នាំ ២០២០ ដោយមានការសម្របសម្រួលពិសេស និងការគាំទ្រពីក្រសួងបរិស្ថានតាមរយៈគម្រោងសាកល្បងដើម្បីដាំដើមម៉ៃសាក់នៅក្នុងដីដែលត្រូវបានរិចរិលទាំងស្រុងចំនួន ១៧០ ហិកតា (៥០ហត សម្រាប់កិច្ចសន្យាទី ១)។ ក្នុងកិច្ចសន្យាទី ១ សហគមន៍ទទួលបានប្រាក់ចំណូលរហូតដល់ទៅ ១. ៣៦៥ លានរៀល ហើយប្រាក់ចំណូល១០% ត្រូវបានចែកដល់រដ្ឋបាលសង្កាត់ និងស្រុក ១០% សម្រាប់តំបន់សត្វព្រៃឱរ៉ាល់ ១០% សម្រាប់ការិយាល័យបរិស្ថានខេត្តកំពង់ស្ពឺ និង ៧០% សំរាប់ CPA ។ បន្ថែមពីនេះ ដោយមានការគាំទ្រពិសេសនិងការសម្របសម្រួលប្រហាក់ប្រហែលគ្នាពីក្រសួងបរិស្ថានក្នុងឆ្នាំ ២០១៩ សហគមន៍ CPA ជើងលាង បានដាំដើមអាកាស្យាលើផ្ទៃដី ២១,២ ហត ដើម្បីផលិតធ្យូងសម្រាប់លក់ដើម្បីកែលម្អជីវភាព[12] ។

រដ្ឋបាលព្រៃឈើកំពុងលើកកម្ពស់កម្មវិធីកសិរុក្ខកម្ម នៅក្នុងសហគមន៍ CFs នៅក្នុងខេត្តមួយចំនួនដែលមានដាំបន្លែ ដើមឈើហូបផ្លែ និងឈើមានគុណភាពខ្ពស់ដែលសហគមន៍អាចប្រមូលផលប្រកបដោយនិរន្តរភាព។ ឧទាហរណ៍ព្រៃខ្មៅ ដើមឈើដែលមានគុណភាពខ្ពស់ គឺដើមធ្នង់ (Pterocarpus Macrocarpus) ចំនួន២៥៧ ត្រូវបានគេដាំនៅក្នុងសហគមន៍ របស់ពួកគេនៅខេត្តកំពត។

[12] ជាថ្មីម្តងទៀត ចំណុចនេះយោងតាមរយៈរបាយការណ៍ស្តីអំពីការពិនិត្យ និងសិក្សាច្បាប់តំបន់ការពារធម្មជាតិ ដើម្បីកែសម្រួលការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (CPA) និងអនុញ្ញាតឲ្យសហគមន៍ដឹកជ ញ្ជូន អនុផលព្រៃឈើ ដែលរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ ដើម្បីស្នើសុំឲ្យមានការកែលម្អ គោលនយោបាយ។ របាយការណ៍បានចែងថា សកម្មភាពពាណិជ្ជកម្មដែលបានអនុញ្ញាតទាំងនេះ មិនត្រូវ បានអនុវត្តស្របតាមច្បាប់ទេ ប៉ុន្តែជាគម្រោងសាកល្បងដែលបានធ្វើជាពិសេស និងកសាងនូវ ឧទាហរណ៍ ឬ ភស្តុតាងដើម្បីគាំទ្រសំណើសុំកែលម្អច្បាប់។

v. ក្រសួងបរិស្ថានកំពុងធ្វើគោលនយោបាយស្តីពីផលិតកម្ម និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការដាក់ស្លាកអេកូ [Sustainable Consumption and Production and Eco-labeling (SCP)] ដែលសង្ឃឹមថានឹងជួយលើកកម្ពស់ការអភិវឌ្ឍផលិតផលអនុផលព្រៃឈើ និងធនធានព្រៃឈើប្រកបដោយចីរភាព។ ការដាក់ស្លាកអេកូនឹងជូនដំណឹងដល់អ្នកទិញអំពីប្រភពផលិតកម្ម របៀបផលិតកម្ម និងការចូលរួមក្នុងផលិតកម្មដែលផ្សារភ្ជាប់ជាមួយនឹងការអភិរក្សធនធានធម្មជាតិ។

vi. ទាំងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិកំពុងត្រូវបាន រៀបចំឆ្ពោះទៅរកការធ្វើវិសោធនកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ ច្បាប់ស្តីពីព្រៃឈើកំពុងត្រូវបានពិនិត្យឡើងវិញ ដោយសទទួលបានការប្តេជ្ញាចិត្តផ្នែកនយោបាយដើម្បីធ្វើវិសោធនកម្ម ក្នុងឆ្នាំ ២០២៣។ គោលបំណងសំខាន់នៃការធ្វើវិសោធនកម្ម គឺដើម្បីផ្ទេរអំណាចទៅអាជ្ញាធរមូលដ្ឋានដើម្បីបង្ក្រាបបទល្មើសនៅនឹងកន្លែង[13]។ ដំណើរការធ្វើវិសោធនកម្មនេះត្រូវបានដឹកនាំដោយក្រសួងមហាផ្ទៃ។ រីឯក្រសួងបរិស្ថានបានមើលឃើញថាការអនុវត្តច្បាប់តំបន់ការពារមិនគាំទ្រនូវតម្រូវការសហគមន៍ ក្នុងការទទួលបានផលពីអនុផលព្រៃឈើនៅឡើយទេ។ ផ្អែកលើបញ្ហានេះ ផ្នែកបច្ចេកទេសនៃក្រសួងបរិស្ថានបានធ្វើការស្នើសុំទៅរដ្ឋមន្ត្រីដើម្បីសុំការគាំទ្រដើម្បីធ្វើវិសោធនកម្មចំណុចមួយចំនួនទាក់ទងនឹងបញ្ហានោះ។

[13] ចំណុចនេះត្រូវបានរាយការណ៍ដោយគេហទំព័រសារព័ត៌មាន ខ្មែរថៃម នាថ្ងៃទី ២៦ កញ្ញា ឆ្នាំ ២០១៨

## ខ) ឱកាសទីផ្សារក្នុងស្រុក៖

មានការទិញជាបន្តបន្ទាប់ និងកាន់តែកើនឡើងពីអ្នកមាន និងអ្នកមធ្យម។ ពួកគេគឺជាគោលដៅចម្បង សម្រាប់ផលិតផលអនុផលព្រៃឈើ ជាពិសេសសម្រាប់ផលិតផលឫស្សី។ អ្នកមានប្រើវាសម្រាប់អាជីវកម្មដូចជារមណីយដ្ឋាន កន្លែងលក់ដីធ្លី ភោជនីយដ្ឋាន និងតម្រូវការក្នុងផ្ទះរបស់ពួកគេ។ តាមពិត ពលរដ្ឋដែលជាអ្នកមានជីវភាពមធ្យម ធ្វើតាមអ្នកមានក្នុងការចាប់ផ្តើមគាំទ្រផលិតផលអនុផលព្រៃឈើបន្ថែមលើទឹកឃ្មុំ និងបន្លែព្រៃ។ល។

សព្វថ្ងៃនេះអ្នកមានចាប់ផ្តើមប្រើផលិតផលឫស្សីសម្រាប់រមណីយដ្ឋាន ការលក់ដី (កញ្ចុះ) ភោជនីយដ្ឋាន និងគ្រឿងប្រើប្រាស់ក្នុងផ្ទះ។ ឥឡូវនេះប្រជាជនដែលជាអ្នកមានមធ្យមកំពុងតែធ្វើតាម ដែលធ្វើឱ្យទីផ្សារនៃផលិតផលឫស្សីកាន់តែកើនឡើង លើសពីនេះ អតិថិជនចង់បានអ្វីប្លែកនិងថ្មីៗ។ ទីផ្សារនៃអ្នកមានមធ្យមទំហំធំ។ *លោកសែម អ៊ីហ្សា ជាម្ចាស់សិប្បកម្មម្លប់ឫស្សី បានរៀបរាប់។*

CF/CPAs អាចរកប្រាក់ចំណូលបានកាន់តែច្រើនតាមរយៈយុទ្ធសាស្ត្រមួយចំនួន។ ទីមួយ បង្កើនច្រវាក់អាជីវកម្មកែច្នៃ៖ វេចខ្ចប់ដោយខ្លួនឯង។ ឧទាហរណ៍ នៅថ្ងៃនេះ សហគ្រាស NTFP ទឹកឃ្មុំ អាចរកប្រាក់បាន ១៦ ដុល្លារក្នុង១លីត្រសម្រាប់ ការលក់ទឹកឃ្មុំដែលមិនទាន់ខ្ចប់។ ប៉ុន្តែ អាចរកបាន រហូតដល់ ចន្លោះពី ២៥ ទៅ ៣០ ដុល្លារក្នុងមួយលីត្រចំពោះទឹកឃ្មុំដែលបានច្រកដប។ ទី២ បង្កើនការលក់នៅក្នុងទីផ្សារ ដែលមានស្រាប់ និងទីផ្សារថ្មី៖ មនុស្សកាន់តែច្រើននឹងទិញ ប្រសិនបើផលិតផលដែលបានផលិតកាន់តែល្អ ហើយផលិតផលត្រូវបានបង្កើន ដោយជំនាញ និងម៉ាស៊ីនទំនើប ការធ្វើទីផ្សារឱ្យប្រសើរជាងមុន តាមរយៈការបង្កើតបណ្តាញ និងផ្សព្វផ្សាយបណ្តាញ រួមទាំងចេះប្រើប្រាស់បណ្តាញសង្គមត្រឹមត្រូវ។ ជាពិសេស តាមហ្វេសបុក (Facebook) នឹង យុទ្ធសាស្ត្រកំណត់តម្លៃល្អ នឹងជួយឱ្យសហគ្រាសអាចរកចំណូលបានល្អ និងមានសមត្ថភាពខាងការប្រកួតប្រជែង។




*កញ្ចុះធ្វើអំពីឫស្សីនៅក្នុងដីរបស់គ្រួសារកម្រិតកណ្តាល គឺ ស្ថានីយ៍ប្រេងឥន្ធនៈ និងផ្ទះ ឬអាហារដ្ឋាន នៅភូមិសាលាលេខ៥ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*

ខណៈពេលដែលទីផ្សារអន្តរជាតិកំពុងរង់ចាំ សហគ្រាស NTFP គួរតែផ្តោតលើការឆ្លើយតបចំពោះតម្រូវការ និងការចង់បានក្នុងស្រុកជាមុនសិន។ វាជាទីផ្សារដែលផ្តល់នូវប្រាក់ចំណូលជាបន្តបន្ទាប់ និងទៀងទាត់សម្រាប់កែលម្អជីវភាពរស់នៅរបស់សហគមន៍ CF/CPA ដែលនឹងអាចរួមចំណែកដល់និរន្តភាពព្រៃឈើ។ ទោះយ៉ាងណាក៏ដោយ គុណភាពជាសេចក្តីត្រូវការចាំបាច់ដែលត្រូវធានាហើយតម្លៃក៏ត្រូវតែល្អ ពោលគឺមានលក្ខណៈប្រកួតប្រជែង។

មុនបញ្ចប់ផ្នែកនេះ វាជាការសំខាន់ណាស់ដែលយើងត្រូវទទួលស្គាល់ថាអនុផលព្រៃឈើបានបម្រើពលរដ្ឋនៅតាមជនបទនៅកម្ពុជាយ៉ាងសំខាន់ និងយ៉ាងសកម្មលើជីវភាពរស់នៅ។

*សូមស្វែងរកឧបសម្ព័ន្ធទី៥ ព័ត៌មានបន្ថែមស្តីពីប្រាក់ចំណូលពីអនុផលព្រៃឈើនិងបម្រើដល់ការចិញ្ចឹមជីវិតនៅតាមជនបទ។*

## គ) ឱកាសទីផ្សារអន្តរជាតិ

ក្រុមហ៊ុនអន្តរជាតិមួយចំនួនដែលអាចទិញ ឬស្រូបយកវត្ថុធាតុដើម ឬផលិតផលអនុផលព្រៃឈើទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេស ទៅកាន់សហរដ្ឋអាមេរិក បណ្តាប្រទេសខ្លះនៅក្នុងសហគមន៍អឺរ៉ុប អង់គ្លេស ជប៉ុន ឬទីផ្សារជុំវិញពិភពលោក។ ពួកគេចាប់អារម្មណ៍នឹងធនធាន និងគុណភាពនៃអនុផលព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ អ្នកខ្លះចង់វិនិយោគនៅខាងក្នុងប្រទេស ខ្លះចង់នាំចេញផលិតផលអនុផលព្រៃឈើ ហើយខ្លះទៀតចង់ធ្វើពាណិជ្ជកម្ម។ **ទោះយ៉ាងណា ដៃគូអន្តរជាតិដែលកម្ពុជាចាប់អារម្មណ៍បំផុតគួរតែជាអ្នកដែលចង់មកកម្ពុជា ហើយវិនិយោគលើការកែច្នៃ និងនាំចេញ។ តម្រូវការនេះស្របពេល ដែលជំនាញបច្ចេកទេសធនធានមនុស្សកម្ពុជានៅមានកម្រិតនៅឡើយ។** នៅក្នុងទីផ្សារសហភាពអឺរ៉ុបត្រូវការគ្រឿងសង្ហារិមអនុផលព្រៃឈើ ឬ សម្ភារៈផ្ទះសម្បែង និងរបស់របរប្រើប្រាស់ដូចជាកន្ត្រក និងទំនិញគ្រួសារផ្សេងៗ។ អ្នកទិញខ្នាតធំ និងយូរអង្វែង ដែលមានចំណាប់អារម្មណ៍ កំពុងប្រតិបត្តិការ និងមានបំណងវិនិយោគ និងធ្វើពាណិជ្ជកម្មនៅកម្ពុជា មានដូចជា ក្រុមហ៊ុន CPL-Teak Farm (កម្ពុជា), LEOPA Bamboo (ខ្មែរ), ហ្វាមីលីកាកាវ (ជាក្រុមហ៊ុនខ្មែរសហការជាមួយក្រុមហ៊ុនកាកាវថៃ), For Front (ក្រុមហ៊ុនខ្មែរសហការជាមួយក្រុមហ៊ុនអាមេរិក ឈ្មោះ Bamboo Surfboard), Bamcore (US), IKEAs (អន្តរជាតិ) និង Tikamoon (អង់គ្លេស) ដែលកំពុងវិនិយោគនៅប្រទេសកម្ពុជា។

ការទន្ទ្រានយកដីព្រៃ និងការកាប់បំផ្លាញព្រៃឈើយ៉ាងគំហុកគឺជាឱកាសមួយសម្រាប់តួអង្គទាំងអស់ ជាពិសេស អង្គការសង្គមស៊ីវិល ពលរដ្ឋមូលដ្ឋាន និងរដ្ឋាភិបាល ធ្វើការរួមគ្នាដើម្បីស្វែងរកមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការដោះស្រាយដើម្បីនិរន្តរភាពព្រៃឈើ។ ផ្អែកលើភាពជាក់ស្តែង ព្រៃឈើមិនទាន់ត្រូវបានរក្សាបានល្អនៅឡើយទេ ប្រសិនបើគ្មានការសហការល្អរវាងតួអង្គខាងលើ រួមទាំងអាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធ។

> រដ្ឋបាលព្រៃឈើមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការទន្ទ្រានយកដីនៅបន្ត និងការកាប់ព្រៃឈើដោយគ្មាននិរន្តរភាព។ ឥឡូវកំពុងធ្វើការ និងស្វែងរកមធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីដោះស្រាយវា។
> *លោក Richard Dansy នាយកប្រតិបត្តិនៃ LEOPA BAMBOO ។*

ផ្អែកលើលទ្ធផលនៃការវិភាគទិន្នន័យបឋម ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃឧត្តមានុវត្តន៍ ឬ ទម្រង់សហគ្រាសអនុផលព្រៃឈើចំនួន ២ នៃខ្សែច្រវាក់ផ្គត់ផ្គង់ដែលអាចនាំទៅរកការកែលម្អអាជីវកម្មចិញ្ចឹមជីវិតរបស់សហគមន៍ CF/CPA និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ឧត្តមានុវត្តន៍១ ក្នុងចំណោមទាំង២នេះ កំពុងដំណើរការនៅប្រទេសកម្ពុជា ប៉ុន្តែនៅមិនទាន់ដំណើរការល្អទេ ដោយសារបញ្ហាទំនួលខុសត្រូវ ភាពជាម្ចាស់ និងបញ្ហាទំនាស់ផលប្រយោជន៍។

ឧត្តមានុវត្តន៍សហគ្រាសអនុផលព្រៃឈើលេខ១៖ ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើតាមរយៈសហគ្រិន ដែលមានចំណូលចិត្តពីធម្មជាតិ [Self-Interested Entrepreneurs (SIE)] មាននៅប្រទេសកម្ពុជា តែអាចផ្គត់ផ្គង់បានតែត្រឹមទីផ្សារក្នុងស្រុកប៉ុណ្ណោះនាពេលបច្ចុប្បន្ននេះ ឧទាហរណ៍ សិប្បកម្មប្លប់ឫស្សី និង ។ល។

### *ក្រាហ្វិចទី២៖ ច្រវាក់ផ្គត់ផ្គង់ - ឧត្តមានុវត្តន៍*




ឧត្តមានុវត្តន៍សហគ្រាសអនុផលព្រៃឈើលេខ២៖ ការធ្វើពាណិជ្ជកម្មតាមអនុផលព្រៃឈើតាមរយៈក្រុមហ៊ុនកែច្នៃអន្តរជាតិ ឬកម្រិតម៉ាក្រូ។ ឧត្តមានុវត្តន៍នេះកំពុងរង់ចាំនៅឡើយ៖




ជាសេចក្តីសន្និដ្ឋាន យើងអាចពង្រឹងសហគ្រាស NTFP និង CF/CPAs ដែលបានបង្កើតហើយ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តចំនួន ៥ នៃប្រទេស ក្រុមហ៊ុន NTFP និងបណ្តាញរបស់ពួកគេ ដើម្បីឆ្ពោះទៅរកទីផ្សារក្នុងស្រុក និងអន្តរជាតិដោយទាញយកឱកាសខាងលើ។

# ៣. បញ្ហាជាក់ស្តែងប្រឈមដោយ CF/CPAs ក្នុងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ ហើយថាតើបញ្ហាទាំងនោះប៉ះពាល់ដល់ការគ្រប់គ្រងដោយនិរន្តរភាព នៃ CF/CPAs យ៉ាងដូចម្តេច




*ក្រាហ្វិចទី៣៖ ដើមឈើបញ្ហា ការវិភាគ និងរូបបង្ហាញនូវបញ្ហាជាក់ស្តែងបំផុត ប្រឈមដោយសហគ្រាសអនុផលព្រៃឈើ*

មានអនុសាសន៍មួយចំនួនដើម្បីដោះស្រាយបញ្ហា ឬ បុព្វហេតុសំខាន់នៃបញ្ហាខាងលើដែលបានផ្តល់ដោយអ្នកសិក្សាជ្រាវ *ប៉ុន្តែ សូមមេត្តាមើលសេចក្តីពិស្តារនៅក្នុងអនុសាសន៍ ដែលផ្តល់ដោយអ្នកស្រាវជ្រាវ នៅបន្ទាប់ អំពី* ***សេចក្តីសន្និដ្ឋាន៖***

ផ្អែកលើការសិក្សានិងការវិភាគខាងលើ ការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើនៃសហគ្រាស NTFP នៅតែប្រឈមនឹងបញ្ហាធំនៅឡើយ ហើយដែលទុកឲ្យនិរន្តរភាពនៃ CFs និង CPAs នៅតែជាបញ្ហាប្រឈមដ៏ធំមួយផងដែរដោយសារតែហេតុផលសំខាន់ៗដូចខាងក្រោម៖

i. ចំណូលមិនគ្រប់គ្រាន់របស់សហគ្រាសអនុផលព្រៃឈើនៃCF/CPAs៖ ប្រាក់ចំណូលមិនគ្រប់គ្រាន់សម្រាប់គាំទ្រសកម្មភាពសហគ្រាស និង ជីវភាពរបស់សមាជិក ហើយក្នុងស្ថានភាពបច្ចុប្បន្ន លទ្ធផលនេះ ហើយដែលសមាជិកសហគ្រាស NTFP នៅតែចាត់ទុកសហគ្រាស NTFP ថាជាសកម្មភាពចិញ្ចឹមជីវិតបន្ទាប់បន្សំប៉ុណ្ណោះ។ នេះដោយសារតែកង្វះចំណាប់ចំណូលចិត្ត និងការប្តេជ្ញាចិត្តច្បាស់លាស់ពីសហគ្រិន សមត្ថភាពកៃច្នៃនៅទាប និងកង្វះខាតឧបករណ៍សមស្រប ឬទំនើប។ កង្វះជំនាញ និងបទពិសោធន៍ខាងការរចនា កង្វះជំនាញអាជីវកម្ម ជាពិសេស ការធ្វើទីផ្សារ និងការលក់ រួមទាំងកង្វះព័ត៌មានអំពីទីផ្សារ។ សំខាន់មួយទៀតគឺ កង្វះខាតដើមទុនហិរញ្ញវត្ថុគឺជាឧបសគ្គធំមួយទៀតដើម្បីដំណើរការ និងជំរុញសហគ្រាសដើម្បីបំពេញតម្រូវការរបស់អតិថិជន។

> ចំណាប់ចំណូលចិត្ត គឺជាកត្តា ដែលមានឥទ្ធិពលខ្លាំងដល់សហគ្រាសកៃច្នៃអនុផលព្រៃឈើ កំណត់នូវជោគជ័យ ឬបរាជ័យ។ បញ្ជាក់ដោយ លោកសែម អ៊ីហ្សា សហគ្រាសឫស្សី ដែលទទួលបានជោគជ័យនៃសិប្បកម្មម្លប់ឫស្សី នៅសាលាលេខ ៥ ខេត្តកំពង់ឆ្នាំង

ដោយសារបញ្ហាខាងលើនេះ បណ្តាលឱ្យថ្នាក់ដឹកនាំ និងសមាជិកសហគ្រាសកែប្រែការផ្តោតអារម្មណ៍របស់ខ្លួន ដោយលែងសូវយកចិត្តទុកដាក់លើអាជីវកម្មរបស់ខ្លួន និងសម្លឹងរកការងារផ្សេងទៀតដែលមានប្រាក់ចំណូលភ្លាមៗ គ្រប់គ្រាន់សម្រាប់គ្រួសារ និងដើម្បីបំពេញនូវការចង់បាននៃជីវិតបែបសម្ភារៈនិយមដូចសព្វថ្ងៃនេះ។ តួយ៉ាង ផលិតកម្មផ្តៅនៅសហគមន៍ដូង និងឃុំព្រៃខ្មៅនៅកំពតបានបញ្ឈប់ដោយសារកង្វះវត្ថុធាតុដើម និងលក់បានថ្លៃទាប។ សហគ្រាសទ្រាំងនៅឆែបកើត នៅខេត្តព្រះវិហារមិនដំណើរការល្អទេដោយសារតែសមាជិកភាគច្រើនវ័យចាស់ ហើយមិនដឹងថាត្រូវលក់ផលិតផលនៅទីណា។

> នៅក្នុងភូមិសមាជិកសហគ្រាស របស់យើងចូលចិត្តជំនាញកែច្នៃ ដែលបានរៀន ប៉ុន្តែដោយសាយើងចាស់ហើយ មិនដឹងពីកន្លែងដែលត្រូវលក់ផលិតផលរបស់យើង ដែលជាហេតុធ្វើឱ្យយើង ដំណើរការមិនបានល្អ។ *លោកយួន រ៉ាត់ប្រធានសហគ្រាស ត្រាំងឆែបកើត។*

បើនិយាយពីអ្នកដឹកនាំសហគ្រាសវិញ ៥០% នៃសហគ្រាសអនុផលព្រៃឈើដើមដូង នៅខេត្តកំពតកំពុងអសកម្ម ហើយមិនទាន់ត្រូវបានជំនួសនៅឡើយ។ ៣៥% នៃអ្នកដឹកនាំសហគ្រាសនៅឃុំព្រៃខ្មៅ និងដំណាក់រលួសកំពុងអសកម្មដែរ។ មូលហេតុចម្បងនៃភាពអសកម្មនេះគឺបណ្តាលមកពីពួកគេត្រូវចេញទៅរកការងារធ្វើ។

ខាងលើនេះបានបង្ហាញថា ប្រាក់ចំណូល និងការគាំទ្រគ្រប់គ្រាន់មានភាពចាំបាច់ដើម្បីឲ្យពលរដ្ឋអាចធ្វើការ និងអាចសកម្មបាន នៅក្នុងសកម្មភាពសហគមន៍របស់ពួកគេ។

ii. កង្វះនៃការគាំទ្រជាមូលដ្ឋានដល់សហគ្រាស NTFP និង CF/CPAs៖

សហគ្រាស NTFP នៃ CFs និង CPAs ត្រូវបានបង្កើតថ្មី ទើបតែបានពីរបីឆ្នាំប៉ុណ្ណោះ។ ពួកគេបានប្រឈមនឹងបញ្ហាជាច្រើន ក្នុងនោះទាំងសមត្ថភាពរៀបចំ និងសមត្ថភាពធ្វើពាណិជ្ជកម្ម។ នេះតម្រូវឱ្យមានការគាំទ្រយូរអង្វែង និងត្រឹមត្រូវ

ពីអ្នកខាងក្រៅ។ សព្វថ្ងៃនេះ CFs និង CPAs បានទទួល ឬទទួលបានការគាំទ្រជាចម្បងពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលមានកម្រិត ខណៈអាយុកាលនៃការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលពឹងផ្អែកលើថវិកាម្ចាស់ជំនួយ។ ប្រសិនបើការគាំទ្រថវិកាពីម្ចាស់ជំនួយត្រូវបានបញ្ឈប់ ការគាំទ្រដល់សហគមន៍ក៏ត្រូវបានបញ្ឈប់ផងដែរ។ ឧទាហរណ៍ CF មួយចំនួននៅខេត្តព្រះវិហារ ដូចជា សង្កែ ឆែបកើត ធ្លាប់ទទួលបានការគាំទ្រពី Winrock និង ពន្លកខ្មែរ ប៉ុន្តែពេលនេះ ការគាំទ្ររបស់អង្គការទាំងពីរនេះបានត្រូវបញ្ឈប់ដោយសារតែអស់ថវិកា។ ដូច្នេះ បានបណ្តាលឱ្យចលនារបស់សហគមន៍មានការថយចុះ។

ក្រៅពីរដ្ឋបាល និងការគាំទ្រផ្នែកច្បាប់ រាជរដ្ឋាភិបាលមិនទាន់មានតួនាទីគួរឱ្យពឹងផ្អែកបាន និងធំដុំនៅឡើយ ក្នុងការគាំទ្រដល់ CF និង CPA និងសហគ្រាស NTFP របស់ពួកគេ ពោលគឺការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ពួកគេដើម្បីនិរន្តរភាព ជាពិសេស ការកែច្នៃអនុផលព្រៃឈើ។

iii. ការប្រមូលផលមិនត្រឹមត្រូវ៖ នៅមានបញ្ហាមួយចំនួននៃការគ្រប់គ្រងលើការប្រមូលផលវត្ថុធាតុដើមដោយត្រឹមត្រូវនៅក្នុង CFs និងCPAs ឬសហគ្រាសអនុផលព្រៃឈើមួយចំនួន។ ឧទាហរណ៍ មានការប្រមូលផលទ្រាំងដោយសមាជិកសហគមន៍ដើម្បីលក់ទៅអ្នកខាងក្រៅ ជាពិសេស ឈ្មួញកណ្តាលជនជាតិវៀតណាមក្នុងបរិមាណរាប់តោនរាល់ខែនៅក្នុងស្រុកឆែប។ មានការប្រមូលទឹកឃ្មុំយ៉ាងអនាធិបតេយ្យ ហើយមិនអនុវត្តតាមគោលការណ៍បច្ចេកទេស៖ ប្រមូលឃ្មុំទាំងមូលដោយមិនទុកឲ្យមានការផលិតទៀតនាពេលអនាគត។ ប្រមូលទឹកឃ្មុំក្មេងដែលមានទឹកឃ្មុំតិច និងមានការប្រជែងប្រមូលទឹកឃ្មុំពីព្រៃដោយគ្មានការបែងចែកភាពជាម្ចាស់លើឃ្មុំដែលបណ្តាលឱ្យមានបញ្ហាចីរភាពដ៏ធំមួយលើការប្រមូលទឹកឃ្មុំ។ ក្នុងចំណោមសហគ្រាសទឹកឃ្មុំដែលត្រូវបានសម្ភាស មានសហគ្រាសចំនួនពីរបានត្អូញត្អែរដូចគ្នាអំពីការប្រមូលផលទឹកឃ្មុំអនាធិបតេយ្យ និងបញ្ហានិរន្តរភាព គឺ សហគ្រាសទឹកឃ្មុំភូមិប្រា និងសហគ្រាសទឹកឃ្មុំគុណភាព២ ។

iv. **ការទន្ទ្រានយកដី៖** ក្នុងចំណោមសហគមន៍ CF/CPAs ទាំង ១០ ដែលបានទៅមើល មាន ៣សហគមន៍នៅតែមានបញ្ហានៃការទន្ទ្រានយកដីពីសំណាក់អ្នកភូមិ ហើយមិនបានដោះស្រាយបានល្អ ផ្អែកលើព័ត៌មានដែលទទួលបានតាមរយៈក្រុមពិភាក្សា។ សព្វថ្ងៃនេះ ឆែបកើតបានបាត់បង់ដីប្រហែល ៥០% នៃដីព្រៃដែលបានផ្តល់ឱ្យធ្វើជា CPA ដោយសារការរំលោភយកដី និងការជីកយករ៉ែ ដែលបានរៀបរាប់ខាងលើមិនទាន់ត្រូវបានដោះស្រាយ និងអាចបញ្ឈប់បាននៅឡើយ ខណៈសហគមន៍ផ្សេងទៀតមិនមានភាពធ្ងន់ធ្ងរ តែមានករណីតូចតាចខ្លះកើតឡើង។

> នៅក្នុង CPA របស់ខ្ញុំ ការរំលោភយកដី និងការកាប់រានខុសច្បាប់គឺធ្ងន់ធ្ងរ ហើយមិនឈប់មិនឈរ។ រហូតមកដល់ពេលនេះសហគមន៍របស់យើងបានបាត់បង់ដីប្រហែល ៥.០០០ ហិចតា ឬ ស្មើនឹងប្រហែល ៥០% នៃផ្ទៃដីព្រៃឈើសរុបដែលបានផ្តល់ឲ្យដោយរដ្ឋ ហើយធ្លាក់ទៅដៃបុគ្គលមួយចំនួន។ *លោក យួន រ៉ាត់ ប្រធានសហគ្រាសទ្រាំង*

v. **ការអនុវត្តច្បាប់៖** មានករណីរំលោភបំពានលើដី និងព្រៃឈើរបស់ CF/CPAs ដែលបានសម្ភាស។ ឧទាហរណ៍នៅមិនទាន់មានវិធានការណាមួយចំពោះអ្នកដែលរំលោភយកដីនៅតំបន់ឆែបកើត CPA ចំពោះការទន្ទ្រានយកដី។ មិនមានសកម្មភាព និងកិច្ចសហប្រតិបត្តិការសមស្របរវាងអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើក្នុងករណីសហគមន៍សង្កែ។ នៅសហគមន៍គុណភាព២ អ្នកភូមិម្នាក់អាចកាន់កាប់ដីរហូតដល់ ៥០០ ហិកតានៅក្នុងដីសហគមន៍ព្រៃឈើ។

vi. **ភាពប្រកួតប្រជែងក្នុងទីផ្សារការងារ៖** សហគ្រាស NTFP របស់ពលរដ្ឋថ្នាក់កណ្តាលក៏កំពុងប្រឈមមុខនឹងកង្វះខាតកម្លាំងពលកម្ម ដោយសារតែមានការកើនឡើងនូវវត្តមានរោងចក្រនៃក្រុមហ៊ុនបរទេសធំៗ ដែលផ្តល់ប្រាក់ខែច្រើនជាងដល់កម្មករ។ ឧទាហរណ៍សហគ្រាសផ្តៅរបស់អ្នកស្រីដួង ម៉ាល័យ មានការយឺតយ៉ាវដោយសារកង្វះកម្លាំងពលកម្ម ហើយជំនួសឱ្យការកែច្នៃសហគ្រាសផ្តៅឥឡូវអ្នកស្រីកំពុងកែច្នៃដបទឹកផ្លាស្ទិចជាជម្រើសមួយ ខណៈពេលកំពុងដោះស្រាយបញ្ហាប្រឈមខាងពលកម្មសម្រាប់ការកែច្នៃផលិតផលផ្តៅ។ បញ្ហានេះកំពុងតែរីករាលដាលយ៉ាងខ្លាំងក្នុងចំណោមសហគ្រាស ដែលមានមូលដ្ឋាននៅតាមសហគមន៍ផ្សេងទៀតដូចជាទ្រាំង ទឹកឃ្មុំ ឬឫស្សីជាដើម ព្រោះអ្នកផលិត

មិនអាចរកចំណូលបានច្រើន និងក៏មិនអាចបំពេញតម្រូវការសេដ្ឋកិច្ចរបស់ពួកគេបានទាន់ពេលវេលា ហើយវាបានជំរុញទឹកចិត្តពួកគេឲ្យធ្វើការឲ្យអ្នកដទៃដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសាររបស់ពួកគេដែលរស់នៅតាមរបៀបជីវិតថ្មីបែបសម្ភារៈនិយមនាពេលសព្វថ្ងៃនេះ។

ផ្អែកលើបញ្ហាប្រឈមខាងលើនេះ និរន្តរភាពព្រៃឈើនៅតែជាក្តីកង្វល់មួយនៅពេលដែលអាជីវកម្មចិញ្ចឹមជីវិត របស់សហគមន៍ CF/CPAs ជាពិសេសសហគ្រាសអនុផលព្រៃឈើនៅតែមានប្រាក់ចំណូលទាប និងមិនគ្រប់គ្រាន់សម្រាប់ការរស់នៅ។ បើគ្មានការគាំទ្រត្រឹមត្រូវ និងគ្រប់គ្រាន់ពីអ្នកខាងក្រៅទេ វាពិបាកសម្រាប់ពួកគេក្នុងការចូលរួមក្នុងការគ្រប់គ្រងធនធានព្រៃឈើ ក្នុងរយៈពេលវែង។ ការលើកទឹកចិត្តរបស់ពួកគេអាចត្រូវបានរីងស្ងួតហួតហែងដោយសារតែកត្តាសេដ្ឋកិច្ច។ ទី២ និរន្តរភាពព្រៃឈើអាស្រ័យលើការគាំទ្រនិងវិធានការប្រកបដោយប្រសិទ្ធភាពពីរដ្ឋបាលព្រៃឈើ ឬក្រសួងបរិស្ថាន និងកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរបច្ចេកទេសពាក់ព័ន្ធ។

## ៤. តើច្បាប់ និងគោលនយោបាយទាក់ទងនឹងអនុផលព្រៃឈើ និងការលើកលែងពន្ធអាចគួរត្រូវកែលម្អយ៉ាងដូចម្តេច ដើម្បីបង្កលក្ខណៈដល់ពាណិជ្ជកម្ម និងការប្រើប្រាស់អនុផលព្រៃឈើ ដោយនិរន្តរភាពដោយ CFs និង CPAs

ការលើកលែងពន្ធត្រូវបានធ្វើឡើងយ៉ាងច្រើនចាប់តាំងពី ៣ ឆ្នាំកន្លងមក ជាពិសេសពន្ធគយ ហើយ CFs/CPAs មួយចំនួនដែលធ្លាប់ទទួលបានការលើកលែងកម្រៃជើងសា និងបុព្វលាភពី MAFF/FA។ មិនតែប៉ុណ្ណោះទេ គេអាចទាញយកឱកាសច្រើនទៀត ដូចខាងក្រោម:

i. តាមរយៈតារាងពន្ធគយជាតិឆ្នាំ ២០១៧ រាជរដ្ឋាភិបាលបានលើកលែងពន្ធជាច្រើន ដូចបានរៀបរាប់នៅក្នុងការរកឃើញទី២ ។ ដូច្នេះដោយសារ ច្បាប់ស្តីពីព្រៃឈើកំពុងត្រូវបានធ្វើវិសោធនកម្ម វាចាំបាច់ណាស់សម្រាប់អង្គការសង្គមស៊ីវិល និងសហគមន៍ដើម្បីពិនិត្យលទ្ធភាពដើម្បីឲ្យថ្លៃបុព្វលាភ និងកម្រៃជើងសាត្រូវបានលើកលែង ដើម្បីឲ្យដើរស្របនឹងគោលនយោបាយជាតិបច្ចុប្បន្ន។ នាពេលបច្ចុប្បន្ននេះដើម្បីស្វែងរក

ការលើងលែងពន្ធលើថ្លៃបុព្វលាភ និងកម្រៃជើងសា គណៈកម្មាធិការសហគមន៍ត្រូវសរសេរលិខិតស្នើសុំយ៉ាងហោចណាស់ឲ្យបានរយៈពេល ១ ឆ្នាំទៅមុខ។ លិខិតស្នើសុំការលើកលែងថ្លៃបុព្វលាភ និងកម្រៃជើងសានេះ គួរតែត្រូវសរសេរសុំការលើកលែងយ៉ាងតិច ៣ ឆ្នាំ និងអនុវត្តតាមជំហានសំខាន់ៗមួយចំនួន គឺ៖ ១) ផ្ញើលិខិតស្នើសុំទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទតាមរយៈខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីការលើកលែងថ្លៃបុព្វលាភ និង កម្រៃជើងសា ២) ដាក់លិខិតស្នើសុំបើកផ្លូវដឹកជញ្ជូន ផ្ញើទៅខណ្ឌរដ្ឋបាលព្រៃឈើ និង ៣) លិខិតស្នើសុំដឹកជញ្ជូនផ្ញើទៅកាន់ផ្នែករដ្ឋបាលព្រៃឈើ (នីតិវិធីត្រូវបានណែនាំសម្រាប់តែសហគមន៍ព្រៃឈើប៉ុណ្ណោះ)[14]. មិនទាន់មានគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរណាមួយសម្រាប់ការស្នើសុំការលើកលែងថ្លៃបុព្វលាភ និងកម្រៃជើងសាត្រូវបានរកឃើញនៅក្រសួងបរិស្ថានទេ អំឡុងពេលសិក្សាស្រាវជ្រាវនៅពេលបច្ចុប្បន្ននេះ។

ii. ជាមួយគ្នានេះដែរ ស្របតាមការរកឃើញ និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន ទាំងច្បាប់ព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ គួរតែសរសេរឲ្យកាន់តែច្បាស់ ឬក៏ថែមមាត្រា ឬឃ្លាមួយអំពីសិទ្ធិ CFs និង CPAs ក្នុងការដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារក្នុងស្រុក។ ដូចគ្នានេះផងដែរ ពួកគេអាចមានសិទ្ធិចុះកិច្ចសន្យាជាមួយក្រុមហ៊ុនណាមួយដើម្បីធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ ប្រកបដោយនិរន្តរភាពជាមួយ CF/CPAs របស់ពួកគេ[15] ឧទាហរណ៍ទិញធនធានអនុផលព្រៃឈើសម្រាប់កែច្នៃ ដាំដើមឈើ ដើមឈើហូបផ្លែ និងដើមឈើឧស្សាហកម្មនៅលើដីដែលរេចរឹល ឬដាំតាមរបៀបចម្រុះនៅក្នុងដីសហគមន៍ ដើម្បីរកប្រាក់ចំណូលសម្រាប់សហគមន៍របស់ពួកគេ។ ដើម្បីឱ្យពួកគេអាចធ្វើបាន រាជរដ្ឋាភិបាលគួរតែបង្កើនរយៈពេលនៃការអនុញ្ញាតសម្រាប់ការគ្រប់គ្រងព្រៃសហគមន៍ពី ១៥ ឆ្នាំទៅយ៉ាងហោចណាស់ ៣០ ឆ្នាំម្តង។ ខាងក្រោមនេះគឺជាបញ្ហាប្រឈម និងចំណុចគួរតែ

---

[14] ផ្អែកលើកំណត់ហេតុនៃការប្រជុំ (Courtesy Call for Meeting) ស្តីអំពីស្តីពីការលើកលែងពន្ធអនុផលព្រៃឈើ ដែលបានធ្វើឡើងនៅទីស្នាក់ការកណ្តាលរដ្ឋបាលព្រៃឈើ កាលពីថ្ងៃទី ១២ ខែសីហាឆ្នាំ ២០១៩។

[15] យោងតាមមាត្រទី ៤៤ នៃច្បាប់ព្រៃឈើ និងមាត្រាទី ២៦នៃច្បាប់តំបន់ការពារធម្មជាតិ៖ សិទ្ធិដែល CFs និង CPAs មិនអាចមាន។

សម្រួលដែលចាំបាច់នៃច្បាប់ CPA ជាសេចក្តីលម្អិតបន្ថែមទៀត ដែលត្រូវបានស្នើឡើងនៅក្នុងក្រសួងបរិស្ថាន[16] ៖

ក. មាត្រា ១១ (ការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ PA ឬតំបន់អាចប្រើប្រាស់បាននៅក្នុងPAs)៖ បញ្ហាប្រឈមនោះគឺសិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចជាលក្ខណៈគ្រួសារអាចត្រូវបានធ្វើតែនៅតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្ស ដែលបានកំណត់ដោយច្បាប់។ ប៉ុន្តែ CPAs អាចធ្វើបានតែនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពតែប៉ុណ្ណោះ។ ដូច្នេះ CPAs គួរតែត្រូវបានធ្វើឡើងទាំងក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងអភិរក្ស។

ជំពូកទី៦ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងជំពូកទី ៩ នៃច្បាប់ ស្តីពីព្រៃឈើ ទាក់ទងនឹងសិទ្ធិប្រើប្រាស់ធនធានព្រៃឈើរបស់សហគមន៍៖

ខ. គួរបន្ថែមមាត្រាមួយនៅក្នុងជំពូកទី៦៖ អនុញ្ញាតឱ្យ CPAs ដឹកជញ្ជូនផលិតផលអនុផលព្រៃឈើពី CPAs ទៅកាន់ទីផ្សារ។ លើសពីនេះទៅទៀត ចំណុចនេះចាំបាច់ត្រូវមានការបញ្ជាក់ឱ្យកាន់តែច្បាស់ក្នុងច្បាប់ស្តីពីព្រៃឈើ នៅជំពូកទី ៩ ផងដែរ។

គ. រយៈពេលនៃការព្រមព្រៀងរវាងក្រសួងនិង CF/CPAs៖ ផ្អែកលើមាត្រា ២៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងមាត្រា២៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើគួរតែមានរយៈពេលច្រើនជាង ១៥ ឆ្នាំដើម្បីអាចឱ្យសហគមន៍មានពេលគ្រប់គ្រាន់ក្នុងការរៀបចំផែនការអភិវឌ្ឍសហគមន៍ និង

---

[16]សូមមើលលេខយោងទី ៩ និង ១២ ខាងលើ៖ **របាយការណ៍ស្តីពីការពិនិត្យច្បាប់ CPA ដើម្បីកែសម្រួលច្បាប់ CPA និងអនុញ្ញាតសហគមន៍ដឹកជញ្ជូនអនុផលព្រៃឈើ** ដែលបានរាយការណ៍ជូនទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ ដើម្បីជាការគាំទ្រឲ្យមានការកែប្រែគោលនយោបាយ និងអនុញ្ញាតឱ្យពួកគេដឹកជញ្ជូនអនុផលព្រៃឈើដែលបានរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ សម្រាប់ការគាំទ្រការផ្លាស់ប្តូរគោល-នយោបាយ។

ឃ. មាត្រា ២៦ (អ្វីដែលសហគមន៍មិនអាចធ្វើបាននៅក្នុង CPAs) នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ និងស្រដៀងគ្នាមាត្រា ២៤ នៃច្បាប់ស្ដីពីព្រៃឈើ៖ គួរតែអនុញ្ញាតឱ្យសហគមន៍ស្វែងរកកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ឬ វិស័យឯកជនសម្រាប់គោលបំណងអភិវឌ្ឍន៍ ឬ ការវិនិយោគលើដីរេចរឹលដើម្បីធ្វើឱ្យប្រសើរឡើងនូវធនធានព្រៃឈើ និងការអភិវឌ្ឍនៅក្នុងសហគមន៍។ ក៏មានការស្នើសុំបន្ថែមមាត្រាមួយដែលអនុញ្ញាតឱ្យ CPAs អាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនសម្រាប់គោលបំណងដែលបានបញ្ជាក់ខាងលើ។

iii. ទោះយ៉ាងណា ផែនការប្រមូលផលប្រកបដោយចីរភាពគួរតែនៅដដែល ឬប្រសើរជាងមុនក៏បានក្នុងន័យលើកកម្ពស់ចីរភាពព្រៃឈើ និងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះការប្រមូលផលយ៉ាងអនាធិបតេយ្យនូវអនុផលព្រៃឈើ ឬយន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ដែលមានប្រសិទ្ធភាពរវាងនាយកដ្ឋានបច្ចេកទេស និងអាជ្ញាធរមូលដ្ឋាននៅពេលដែលច្បាប់បច្ចុប្បន្នមិនបានចែង ដូចបានពិពណ៌នាខាងលើ។

iv. រាល់ការអនុញ្ញាតលើការនាំចេញអនុផលព្រៃឈើ គួរតែត្រូវបានធ្វើ ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជំនួសឱ្យទីស្ដីការគណៈរដ្ឋមន្ត្រី បើទោះជាផ្ដៅក៏ដោយ ដើម្បីកាត់បង្រួញនូវដំណើការស្នើសុំនាំចេញ [មាត្រា ២៦ ឬជំពូកទី ៧ នៃច្បាប់ស្ដីពីព្រៃឈើ និងទំព័រទី ៧ នៃសៀវភៅណែនាំស្ដីពីនីតិវិធីនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ខែមេសាឆ្នាំ ២០០៨៖ លិខិតអនុញ្ញាតនាំចេញ និងលិខិតអនុញ្ញាត (Export License and Permit Letter]។

# សេចក្តីសន្និដ្ឋាន

ការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើក្នុងប្រទេសកម្ពុជាកំពុងទទួលបានក្តីសង្ឃឹមសម្រាប់ការអភិវឌ្ឍកាន់តែប្រសើរតាមរយៈគោលនយោបាយជាតិ និងកិច្ចខិតខំរបស់ប្រទេសកម្ពុជាកាន់តែប្រសើរឡើងចាប់តាំងពីមានការផ្លាស់ប្តូរយ៉ាងធំចំពោះការលើកលែងពន្ធ ជាពិសេសក្នុងការនាំចេញផលអនុផលព្រៃឈើ។ ទី១ ច្បាប់សំខាន់ពីរគឺច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ កំពុងត្រូវបានធ្វើវិសោធនកម្ម និងពិនិត្យឡើងវិញ ក្នុងគោលបំណងដើម្បីគ្រប់គ្រងព្រៃឈើ និងលើកកម្ពស់ជីវភាពសហគមន៍កាន់តែប្រសើរ។ ទី២ មានសេចក្តីត្រូវការ និងការចង់បានកើនឡើងសម្រាប់ផលិតផលអនុផលព្រៃឈើទាំងនៅក្នុងទីផ្សារក្នុងស្រុក និងអន្តរជាតិដែលផ្តល់ឱ្យសហគ្រាសនៃអនុផលព្រៃឈើនូវលំហូរនៃប្រាក់ចំណូលជាពិសេសផលិតផលឫស្សី។ ទី៣ វិនិយោគិន និងអ្នកទិញ NTFP ជាច្រើនកំពុងពិចារណា និងរង់ចាំបើកអាជីវកម្មរបស់ខ្លួនជាមួយប្រទេសកម្ពុជា។ ទី៤ ប្រទេសកម្ពុជាមានអនុផលព្រៃឈើ និងដីមានជីវជាតិរួមទាំងដំណាំដែលមានតម្លៃថ្លៃៗ ផ្សេងទៀតរួមទាំងដើមឈើឧស្សាហកម្មសម្រាប់រកចំណូលបានខ្ពស់សម្រាប់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ទី៥ មានសេចក្តីត្រូវការ និងការចង់បានដែលកំពុងលេចចេញនូវផ្លែឈើដែលមានតម្លៃថ្លៃ និងឈើឧស្សាហកម្ម ដូចជាដើមម៉ៃសាក់ ឈើមានគុណភាពខ្ពស់ ដូចជា ដើមឈើអាកាស្យាជាដើមដែលអាចដាំតាមរបៀបបញ្ចូលគ្នាក្នុង CF/CPAs អាចរកប្រាក់ចំណូលបានយ៉ាងច្រើនសម្រាប់កែលម្អជីវភាពរស់នៅរបស់សហគមន៍ និងនិរន្តរភាពព្រៃឈើ។ ទី៦ CF/CPAs សហគ្រាស NTFP ដែលទទួលបានការអនុញ្ញាត កំពុងបោះជំហានទៅរកកម្រិតពាណិជ្ជកម្មបន្ទាប់ទៀត និងឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចនាពេលអនាគត។

គុណភាពនៃផលិតផលនៅតែជាបញ្ហាចម្បងដែលនាំឱ្យមានប្រាក់ចំណូលទាប និងជាកត្តាដ៏សំខាន់សម្រាប់បង្កើតនូវសហគមន៍ និងសហគ្រាសប្រកបដោយចីរភាព ជាពិសេសផលិតផលផ្តៅ ឫស្សី និងផលិតផលទ្រាំងទាំងឡាយ។

ខណៈដែល ទីផ្សារអន្តរជាតិ ឬអ្នកវិនិយោគបរទេសកំពុងរង់ចាំទីផ្សារក្នុងស្រុកនៅតែជាប្រភពចំណូលល្អដដែល ព្រោះមានកំណើននៃការទិញអនុផលព្រៃឈើ ជាពិសេសក្នុងចំណោមពលរដ្ឋមានជីវភាពមធ្យមដើម្បីធ្វើអាជីវកម្ម និងរបស់របរប្រើប្រាស់ក្នុងផ្ទះ ហើយពួកគេជាអ្នកដែលមានសក្តានុពលក្នុងការទិញផលិតផលអនុផលព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយពួកគេក៏ចង់បានផលិតផលដែលមានគុណភាពខ្ពស់ផងដែរ។ ទោះជាយ៉ាងណា ត្រូវប្រាកដថា យុទ្ធសាស្ត្រទីផ្សារ និងការលក់មានភាពប្រកួតប្រជែងគ្រប់គ្រាន់។

**គុណភាពល្អ + តម្លៃល្អ + ទំហំនៃបរិមាណសម្រាប់លក់ល្អ = ប្រាក់ចំណូលច្រើន
នេះជាចីរភាពនៃអាជីវកម្ម។**

លើសពីនេះទៀត ចីរភាពនៃសហគ្រាស NTFP ទាមទារឲ្យមានសហគ្រិន ដែលមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនពីធម្មជាតិ។ នេះគឺជាស្នូលនៃចំណុចចាប់ផ្តើម។ យើងគួរតែលើកកម្ពស់ពួកគេឱ្យកាន់តែប្រសើរ និងរួមបញ្ចូលគោលដៅរបស់យើងជាមួយអាជីវកម្ម ដែលមានស្រាប់របស់ពួកគេ ហើយធ្វើឱ្យពួកគេក្លាយជាអ្នកនាំមុខនៃវិស័យនេះ និងក្លាយជាអ្នកទិញផលិតផលអនុផលព្រៃឈើសម្រាប់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ការរៀបចំប្រកបដោយនិរន្តរភាពនៃការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើគឺជាការធ្វើការរួមបញ្ចូលរវាងកិច្ចខិតខំប្រឹងប្រែងឯកជន និងកិច្ចខិតខំប្រឹងប្រែងរួម និងចែករំលែកផលប្រយោជន៍ ឬផលចំណេញ។ វាមិនអាចធ្វើបានដោយសហគ្រាស NTFP តែឯងបានឡើយ ស្របតាមវប្បធម៌សព្វថ្ងៃនេះ។

ការលើកលែងពន្ធគឺមានភាពទាក់ទាញដល់អ្នកទិញអន្តរជាតិ ប៉ុន្តែយើងត្រូវផ្សព្វផ្សាយព័ត៌មាននេះឲ្យពួកគេយល់ដឹង ហើយរួមគ្នាបង្វែរកិច្ចខំប្រឹងប្រែងពីការលើកលែងពន្ធ មកកិច្ចខំប្រឹងប្រែង លើការដោះស្រាយនីតិវិធីស្មុគស្មាញ និងថ្លៃសេវាក្រៅផ្លូវការវិញម្តង។ ជាចុងក្រោយ តែក៏ជាចំណុចសំខាន់ដែរនោះ គឺថា កិច្ចខំប្រឹងប្រែងរួមគ្នារវាងអ្នកពាក់ព័ន្ធក្នុងវិស័យអនុផលព្រៃឈើរួមទាំងក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ នីតិវិធី និងការអនុវត្តដែលមានភាពស្មុគស្មាញគឺគួរត្រូវបានធ្វើ។ ការខិតខំរួមគ្នាសម្រាប់

ចំណុចទាំងពីរនេះចាំបាច់ ត្រូវបានធ្វើដោយមានផែនទីបង្ហាញផ្លូវជាយុទ្ធសាស្ត្រមួយ (a strategic road map)។

នៅកម្រិតគោលនយោបាយ ដើម្បីបម្រើសិទ្ធិពេញលេញរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់អនុផលព្រៃឈើ ធានាការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងលើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍ឱ្យកាន់តែប្រសើរ ការធ្វើវិសោធនកម្មទាំងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិគឺចាំបាច់ណាស់។ ជាសំខាន់គឺ គួរឲ្យមានរយៈពេលនៃការព្រមព្រៀងរវាងក្រសួង និង CF/CPAs យ៉ាងតិចបាន ៣០ឆ្នាំម្តងដើម្បីឱ្យមានការវិនិយោគយូរជាងនេះពាក់ព័ន្ធនឹងការអភិវឌ្ឍអាជីវកម្មចិញ្ចឹមជីវិត។ អនុញ្ញាតឱ្យ CF/CPAs ចុះកិច្ចសន្យាជាមួយក្រុមហ៊ុន (វិស័យ) ឯកជនលើការវិនិយោគរយៈពេលវែងក្នុងការលើកកម្ពស់ជីវភាពសហគមន៍ និងការអភិវឌ្ឍមូលដ្ឋានចេញពីធនធានព្រៃឈើ និងធនធានដែលពាក់ព័ន្ធ។ ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិគួរតែបញ្ជាក់ឲ្យកាន់តែច្បាស់ និងអនុញ្ញាតឱ្យទាំង CF និង CPA ដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារ ដោយជួយបង្កភាពងាយស្រួលដល់សកម្មភាពពាណិជ្ជកម្មរបស់សហគមន៍ ទាំង CF និង CPA ហើយពួកគេគួរទទួលបានការលើកលែងពន្ធលើបុព្វលាភ និងកម្រៃជើងសា លើការប្រមូលផលអនុផលព្រៃឈើដើម្បីឱ្យស្របនឹងគោលនយោបាយជាតិដែលបានធ្វើឡើងលើការលើកលែងពន្ធ។

# អនុសាសន៍របស់អ្នកសិក្សាស្រាវជ្រាវ

ដើម្បីជំនះលើការប្រឈមខាងលើទាក់ទងនឹងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ អ្នកសិក្សាស្រាវជ្រាវសូមជូនអនុសាន៍មួយចំនួន ដូចខាងក្រោម៖

## អនុសាសន៍រួមសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសសហគ្រិនទាំងឡាយ៖

i. អ្នកពាក់ព័ន្ធក្នុងការធ្វើពាណិជ្ជកម្មនៃអនុផលព្រៃឈើ គួរតែផ្តោតលើការពង្រឹង និងពង្រីកពាណិជ្ជកម្មផលិតផលអនុផលព្រៃឈើសម្រាប់ទីផ្សារ ក្នុងស្រុកជាអាទិភាពទីមួយ មុនពេលឈានជើងចូលទីផ្សារអន្តរជាតិ។ មានតម្រូវការ និងការចង់បានជាច្រើនដើម្បីបំពេញក្នុងចំណោមអតិថិជនដែលមានស្រាប់ និងពង្រីកការលក់ក្នុងចំណោមអ្នកមាន និងអ្នកមធ្យមនៅក្នុងប្រទេសកម្ពុជា។ ការវេចខ្ចប់ត្រឹមត្រូវគួរតែត្រូវបានធានា និងបញ្ចូលជាមួយនូវស្លាកបែតង និងការលក់តាមអ៊ិនធឺណេត និងទីផ្សារឌីជីថល (online and digital marketing) ឱ្យបានត្រឹមត្រូវ ជាពិសេសតាមរយៈហ្វេសប៊ុក។ គួរពិចារណានូវមុខនាទីអ្នកជំនាញខាងទីផ្សារ និងលក់ត្រឹមត្រូវណាមួយមកឲ្យជួយបំពេញក្នុងតម្រូវការនេះ និងផ្តល់ការគាំទ្រជាយុទ្ធសាស្រ្ត

ii. ដោយសារមានគោលនយោបាយលើកលែងពន្ធច្រើនអ្នកពាក់ព័ន្ធក្នុងវិស័យអនុផលព្រៃឈើគួរតែបង្វែរកិច្ចខំប្រឹងប្រែងរបស់ខ្លួនពីការស្វែងរកមធ្យោបាយសុំការលើកលែងពន្ធ ទៅនីតិវិធីងាយស្រួលសម្រាប់ការនាំចេញវិញ;

iii. ឆ្លៀតឱកាសដែលនឹងមកដល់នៃការធ្វើវិសោធនកម្មច្បាប់ទាំងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ភាគីពាក់ព័ន្ធអនុផលព្រៃឈើគួរតែ៖
   - ➢ តស៊ូមតិដើម្បីសម្រួលរយៈពេលនៃដំណើរអនុវត្ត CF/CPAs ឲ្យបានយ៉ាងហោចណាស់ ៣០ឆ្នាំជំនួសឱ្យរយៈពេល ១៥ ឆ្នាំដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការវិនិយោគរយៈពេលវែង រួមទាំងការច្នៃប្រឌិតប្រាក់ចំណូលរបស់ CF/CPA ក្នុងការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើ។
   - ➢ តស៊ូមតិដើម្បីពង្រីកសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការដំណើរការ CF/CPAs ដើម្បីអាចចុះកិច្ចសន្យាជាមួយអង្គការវិស័យឯកជនក្នុងការធ្វើពាណិជ្ជកម្មលើអនុផលព្រៃឈើ និងការវិនិយោគរយៈពេលវែងដែលពាក់

ព័ន្ធ ដូចជាការដាំរុក្ខជាតិឧស្សាហកម្មនៅលើដីរេចរឹល ឬតាមរបៀបចម្រុះការដាំឈើមានគុណភាព និងដំណាំឈើឧស្សាហកម្ម ជាដើម ដែលអាចជួយរកប្រាក់ចំណូលបានច្រើនសម្រាប់ជីវភាព និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន។

- ក្នុងការពង្រីកសិទ្ធិរបស់សហគមន៍មូលដ្ឋាន CF/CPAs សហគមន៍ អនុផលព្រៃឈើគួរតែរកការគាំទ្រដើម្បីមានសិទ្ធិដឹកជញ្ជូនអនុផលព្រៃឈើទៅកាន់ទីផ្សារផងដែរ។
- អ្នកពាក់ព័ន្ធក្នុងវិស័យអនុផលព្រៃឈើគួរតែធ្វើការគាំទ្រដើម្បីទទួលបានការមិនយកថ្លៃបុព្វលាភ និងកម្រៃជើងសា សម្រាប់សហគមន៍ CF/CPAs ដែលទទួលបានការឯកភាពលើផែនការប្រមូលផលប្រកបដោយនិរន្តរភាព។

យោងតាមការរកឃើញ កម្រិតនៃជោគជ័យនៃការងារនេះគឺមាន កម្រិតខ្ពស់ ព្រោះចំណុចទាំងនេះកំពុងត្រូវបានពិនិត្យលើការធ្វើវិសោធនកម្មច្បាប់ស្ដីពីតំបន់ការពារធម្មជាតិនៅឯក្រសួងបរិស្ថាន និង ការធ្វើវិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ ដែលគ្រោងធ្វើនៅឆ្នាំ ២០២៣ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដឹកនាំដោយក្រសួងមហាផ្ទៃ;

iv. កិច្ចខិតខំប្រឹងប្រែងរួមគ្នា៖ សហគ្រាសអនុផលព្រៃឈើ ដែលមានមូលដ្ឋាននៅក្នុងសហគមន៍ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលគួរតែធ្វើការរួមគ្នា ដើម្បីលើកកម្ពស់ដំណើរការ និងការនាំចេញផលិតផលអនុផលព្រៃឈើ។ អង្គការសង្គមស៊ីវិលគួរតែសិក្សាពីផែនការដែលមានស្រាប់របស់រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ហើយចូលរួម និងជួយបង្កលទ្ធភាព ឱ្យពួកគេអនុវត្តគម្រោងបានកាន់តែប្រសើរ។ គម្រោងដែលមានកិច្ចសហការ បែបនេះអាចត្រូវបានអនុវត្ត និងបន្តទៅមុខជាជំហានៗ និងផ្អែកតាមមូលដ្ឋាននៃលទ្ធផល (outcome based)។ តួអង្គនីមួយៗ គួរដើរតួទៅតាមតួនាទីខុសៗគ្នាតាមសមរម្យ។ ឧទាហរណ៍សហគមន៍ ឬសហគ្រាសអនុផលព្រៃឈើទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធាន និងផ្គត់ផ្គង់ធនធាន ឬផលអនុផលព្រៃឈើ។ រដ្ឋាភិបាល គួរតែទទួលខុសត្រូវក្នុងការគាំទ្រការដឹកជញ្ជូន នីតិវិធីនាំចេញ និងកិច្ចការរដ្ឋបាល ឬការសម្របសម្រួលពាក់ព័ន្ធនឹងអនុផលព្រៃឈើ និងស្វែងរកទីផ្សារ។ ការ

បន្ថែមអង្គការសង្គមស៊ីវិលគួរតែទទួលខុសត្រូវក្នុងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលពាក់ព័ន្ធ ហើយវិស័យឯកជនគួរតែទទួលខុសត្រូវលើការកែច្នៃ និងនាំចេញ។ ដើម្បីធានាកុំឲ្យមាននូវទំនាស់ផលប្រយោជន៍ ការធ្វើសេចក្តីសម្រេចបែបប្រជាធិបតេយ្យគួរតែធ្វើឡើងដើម្បីធ្វើគោលនយោបាយ និងការគ្រប់គ្រងប្រតិបត្តិការសំខាន់ៗ។ គម្រោងគួរតែមានក្រុមប្រឹក្សាភិបាលរួមមួយដែលមានសំឡេង ស្មើគ្នាដើម្បីធ្វើសេចក្តីសម្រេច និងមានគណៈកម្មាធិការប្រតិបត្តិការនិងគណៈកម្មាធិការបច្ចេកទេសរួមគ្នា។ វានឹងលើកកម្ពស់ភាពជាម្ចាស់ពិតប្រាកដ និងជំនះឧបសគ្គក្នុងការលើកកម្ពស់វិស័យនេះឱ្យកាន់តែប្រសើរឡើង។ គំនិតនេះអាចត្រូវបានចាប់ផ្តើមដោយគម្រោងសាកល្បង និងមានការវាយតម្លៃ និងពង្រីកតាមតម្រូវការជាក់ស្តែង;

v. នៅតែមានតម្រូវការចាំបាច់ដើម្បីឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការអភិរក្ស និងដាំដើមឈើឡើងវិញដើម្បីធ្វើឲ្យមានភាពសម្បូរបែបនូវប្រព័ន្ធអេកូឡូស៊ី និងធនធានអនុផលព្រៃឈើ។ នេះអាចធ្វើទៅបាន តាមរយៈភាពជាដៃគូ និងការតស៊ូមតិរួមគ្នា។ ដំណោះស្រាយរួមគ្នា គួរតែឆ្លុះបញ្ចាំងពីបញ្ហាពិត ដែលកំពុងកើតឡើងនៅមូលដ្ឋានឬសហគមន៍ ដូចជាការទន្ទ្រានយកដី និងការប្រមូលផលអនាធិបតេយ្យនៅក្នុងតំបន់ CF និងCPAs។ ការបញ្ឈប់ការកាប់ ទុកឱកាសឲ្យឈើដុះឡើងវិញ ជាដំណោះស្រាយល្អបំផុត។ ទោះយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវធ្វើដោយ មានការគាំទ្រពី FA និង MoE ដោយមានការចូលរួមពីសហគមន៍ទាំងឡាយ; និង

vi. ការដាំដើមឈើ ដែលមានគុណភាព និងសម្រាប់ឧស្សាហកម្មនៅក្នុងតំបន់ ដែលមានការរេចរឹលក្នុង CF/CPAs បានក្លាយជាសញ្ញាលេចធ្លោនៃប្រភពចំណូលដែលមានសក្តានុពល និងដុំកំភួនសម្រាប់សហគមន៍។ ទោះជាយ៉ាងណា វាជាប្រធានបទត្រូវសិក្សាបន្ថែម និងធ្វើឱ្យប្រាកដថា សកម្មភាពប្រភេទនេះអាចគាំទ្រ CF /CPAs ឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

i. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គួរតែបង្កើនការគាំទ្រដល់ពាណិជ្ជកម្មផលអនុផលព្រៃឈើនៃ CFs ឬCPAs តាមរយៈការបង្កើនធាតុចូលរបស់ខ្លួនទៅក្នុងការវិនិយោគហិរញ្ញវត្ថុសម្រាប់ការបង្កើនដើមទុន និងគ្រឿងម៉ាស៊ីនទំនើបៗ ការកៀរគរអ្នកវិនិយោគ ឬអ្នកទិញមកពីជុំវិញពិភពលោកតាមរយៈការទូត និងបណ្ដាញរបស់ខ្លួនដោយបង្កើតវិធីសាមញ្ញ សម្រាប់ការអនុញ្ញាតនាំចេញ។ ផ្ដល់ការគាំទ្រ និងការការពារផ្នែករដ្ឋបាល នៅតាមដងផ្លូវដល់ការដឹកជញ្ជូនផលិតផលអនុផលព្រៃឈើ គឺត្រូវប្រាកដថាមិនមានការសម្របសម្រួលខ្សោយ និងបញ្ហាការបង់ប្រាក់ក្រៅផ្លូវការពីមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ និងនីតិវិធីសាមញ្ញសម្រាប់ការនាំចេញ;

ii. ដើម្បីឲ្យស្របនឹងគោលនយោបាយរបស់រាជរដ្ឋភិបាលលើការលើកលែងពន្ធលើការនាំចេញ ច្បាប់ (ព្រៃឈើ; តំបន់ការពារធម្មជាតិ) គួរតែអនុញ្ញាតឱ្យ CF និង CPAs ដែលបានអនុញ្ញាតហើយមានផែនការប្រមូលផលប្រកបដោយនិរន្តរភាពទទួលបានការមិនយកថ្លៃបុព្វលាភ និងកម្រៃជើងសាដោយស្វ័យប្រវត្តិ ខណៈច្បាប់ព្រៃឈើកំពុងត្រូវបានធ្វើវិសោធនកម្ម។ បង្កើនរយៈពេលនៃការអនុញ្ញាតឱ្យដំណើរការ CF/CPAs ដែលមានការអនុញ្ញាតដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការប្តេជ្ញាចិត្តយូរអង្វែងរបស់សហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ និងអនុញ្ញាតឱ្យពួកគេមានសិទ្ធិចុះកិច្ចសន្យាវិនិយោគជាមួយវិស័យឯកជនដើម្បីលើកកម្ពស់អនុផលព្រៃឈើ និងសកម្មភាពពាណិជ្ជកម្ម ដែលអាចធ្វើបាន ដូចជាបន្ត និងពង្រីកកសិ-រុក្ខកម្ម ការដាំដើមឈើថ្មីៗតាមវិធីសាស្រ្តចម្រុះ ឬនៅតំបន់រេចរឹលនានា។ល។ បន្ថែមសេចក្តីពិពណ៌នាឲ្យបានកាន់តែច្បាស់ថា CF/CPAs ដែលមានផែនការប្រមូលផលប្រកបដោយនិរន្តរភាពអាចដឹកជញ្ជូនផលិតផលអនុផលព្រៃឈើរបស់ពួកគេទៅទីផ្សារបាន;

iii. នីតិវិធីនៃការនាំចេញ៖ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានភាពសាមញ្ញលើនីតិវិធីនៃការនាំចេញ ពោលគឺ ខ្ពស់បំផុត ការអនុញ្ញាតឲ្យការនាំចេញគួរតែត្រូវបានធ្វើឡើង ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឱ្យទីស្ដីការគណៈរដ្ឋមន្ត្រី;

iv. គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអនុផលព្រៃឈើគួរត្រូវបានសរសេរដើម្បីណែនាំ CF/CPAs និងអ្នកពាក់ព័ន្ធ អំពីរបៀបគ្រប់គ្រង និងការរៀបចំដំណើរការសហគ្រាស NTFP ដើម្បីឲ្យពួកគេមានគំនិត ឬ រូបភាពច្បាស់លាស់លើបញ្ហានេះ ដោយមិនអនុវត្តផ្ទុយ ឬរំលោភលើច្បាប់ ឬអនុក្រឹត្យពាក់ព័ន្ធនឹងព្រៃឈើ; និង

v. រាជរដ្ឋាភិបាលកម្ពុជាគួរបំបែកផលអនុផលព្រៃឈើចេញពីបញ្ជីឈើ (timber list) នៅក្នុងឯកសារច្បាប់ ដែលវាជួយឱ្យដំណើរការ និងនីតិវិធីធ្វើពាណិជ្ជកម្មមានភាពងាយស្រួល និងសាមញ្ញ។

## អនុសាសន៍សម្រាប់ភ្នាក់ងារគាំទ្រទាំងឡាយ៖

i. ខណៈពេលដែលកំពុងផ្សព្វផ្សាយអនុផលព្រៃឈើនៅក្នុងទីផ្សារក្នុងស្រុក ភ្នាក់ងារគាំទ្រអនុផលព្រៃឈើ គួរបន្តការលើកកម្ពស់វិនិយោគិនបរទេសឱ្យធ្វើវិនិយោគនៅក្នុងការផលិត ឬកែច្នៃឧស្សាហកម្មខ្នាតធំ ហើយ ដែលមានលក្ខណៈស្អាត ឬបៃតងផង។ ភ្នាក់ងារគាំទ្រអនុផលព្រៃឈើ គួរតែផ្តល់ព័ត៌មានដល់ក្រុមហ៊ុន និងវិនិយោគិនធំៗ (អន្តរជាតិ) ជាថ្មីម្តងទៀតអំពីការប្រែប្រួលលើការលើកលែងពន្ធ ជាពិសេសពន្ធលើផលិតផលអនុផលព្រៃឈើ ដែលមានការកែច្នៃ និងលើកទឹកចិត្តអ្នកមានសក្តានុពលឱ្យចាប់ផ្តើមកែច្នៃ និងនាំចេញ;

ii. ការសម្របសម្រួល និងគាំទ្រសហគ្រាស ឬក្រុមហ៊ុនអនុផលព្រៃឈើ គួរតែត្រូវបានសម្របសម្រួលដោយយកចិត្តទុកដាក់ លើចំណុចចីរភាព ដូចជាថ្លៃឈ្នួល ប្រាក់ខែ និងចំណាយប្រតិបត្តិការ ផ្សេងទៀត ដូចជា ទីតាំង ការិយាល័យ ឬ ការជួលដែលមានតម្លៃធូរជាដើម។ មធ្យោបាយល្អបំផុត គឺចូលរួមប្រើប្រាស់ធនធានដែលមានស្រាប់របស់សហគមន៍ ឬសមាជិកម្នាក់ៗ ដោយការចែករំលែកនូវអត្ថប្រយោជន៍ទៅវិញទៅមកដែលអាចធ្វើទៅបាន។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ ៖ ឯកសារយោង (ទិន្នន័យបន្ទាប់បន្សំ)

ខាងក្រោមនេះជាឯកសារយោងដែលអ្នកសិក្សាស្រាវជ្រាវបានសិក្សា៖

**គោលនយោបាយពាក់ពន្ធ័៖**

- **សៀវភៅណែនាំស្តីពីនីតិវិធីនាំចេញ៖ មគ្គុទេសក៍ជាក់ស្តែងសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា** ខែមេសាឆ្នាំ ២០០៨ ក្រសួងពាណិជ្ជកម្ម និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)
- **ក្រមបរិស្ថាន និងធនធានធម្មជាតិនៃកម្ពុជា** កំណែទី ១១, ២០ ខែមេសា ឆ្នាំ ២០១៩ ក្រសួងបរិស្ថាន
- **ច្បាប់ស្តីពីព្រៃឈើ** ឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជា។
- **ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ** ឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជា។
- **ច្បាប់ស្តីពីសារពើពន្ធ**, ខែមករាឆ្នាំ ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា។
- **បញ្ជីនៃបុព្វលាភ និងកម្រៃជើងសាលើឈើ និងផលិតផលអនុផលព្រៃឈើ** គ្មានកាលបរិច្ឆេទ, MAFF
- **លិខិតនៃការធ្វើបច្ចុប្បន្នភាពលើឧបសម្ព័ន្ធ១ នៃអនុក្រឹត្យ ស្តីអំពីការដាក់ឱ្យអនុវត្តនូវបញ្ជីទំនិញហាមឃាត់ និងមានកំណត់ ...** លេខ ៣៧៨៤ សហវ អគរ ចុះថ្ងៃទី ១៩ ខែមិថុនាឆ្នាំ ២០១២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **កំណត់ហេតុនៃការប្រជុំ (Courtesy Call for Meeting) ស្តីពីការលើកលែងពន្ធអនុផលអនុផល**, ទីស្នាក់ការកណ្តាលនៃរដ្ឋបាលព្រៃឈើ, ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៩ ។
- **កម្មវិធីគោលនយោបាយជាតិ៖** ឆ្នាំ២០១០-២០២៩, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- **អនុក្រឹត្យស្តីពីអនុផលព្រៃឈើ និងមិនមែនឈើអនុញ្ញាតឱ្យនាំចេញ និងនាំចូល** ខែវិច្ឆិកាឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជា (RGC) និង ឧបសម្ព័ន្ធរបស់វា៖ **ដំណើរការ នៃការស្នើសុំនាំចេញ និងនាំចូលផលិតផលព្រៃឈើ។**

- **អនុក្រឹត្យ ស្តីពី ការដាក់ឲ្យដំណើរការបញ្ជីទំនិញដែលត្រូវបានហាមឃាត់ និងមានកំណត់,** ធ្នូ ២០០៧, រដ្ឋាភិបាល (RGC)។
- **អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ** ២០០៣, រាជរដ្ឋាភិបាលកម្ពុជា (RGC)។
- **ក្របខណ្ឌការងារ (ToR) ការធ្វើការសិក្សាអំពីវិសាលភាព និងការធ្វើផែនទីបង្ហាញផ្លូវស្តីពីផលិតកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព**នាយកដ្ឋានសេដ្ឋកិច្ចបៃតង អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ខែកញ្ញាឆ្នាំ២០២០។

## ឯកសារយោងផ្សេងៗទៀត៖

- **ការវាយតម្លៃគោលនយោបាយរបស់អនុផលព្រៃឈើលើផលិតផលអនុផលព្រៃឈើ,** Edna Maguigat, 2020, NTFP-EP
- **គោលនយោបាយពាណិជ្ជកម្មផ្តៅកម្ពុជា សង្ខេប និងអនុសាសន៍ទី២** ខែមិថុនា ឆ្នាំ ២០១១ លោក Todd Sigaty ទីប្រឹក្សាអន្តរជាតិ នៃអង្គការ WWF
- **អាជ្ញាធរកម្ពុជាធ្វើដំណើរទៅធ្វើវិសោធនកម្មច្បាប់ក្នុងកិច្ចប្រឹងប្រែងការពារព្រៃឈើ** ថ្ងៃទី ៣០ ខែវិច្ឆិកាឆ្នាំ ២០១៨ វិទ្យុអាស៊ីសេរី
- **សេចក្តីព្រាងនៃរបាយការណ៍ស្តីពីការពិនិត្យ និងសិក្សាច្បាប់ស្តីពីតំបន់ការពារធម្មជាតិដើម្បីកែសម្រួលការរៀបចំសហគមន៍ការពារធម្មជាតិ CPAs និងអនុញ្ញាតឱ្យសហគមន៍ដឹកជញ្ជូនអនុផលព្រៃឈើ** មិនមានកាលបរិច្ឆេទជាក់លាក់ទេ ប៉ុន្តែនៅឆ្នាំ២៥៦៤/២០២០ ធ្វើដោយនាយកដ្ឋានជីវភាព
- **សេចក្តីព្រាងលិខិតស្នើលើកលែងបុព្វលាភ និងកម្រៃជើងសា ផ្តៅ និងឫស្សីនៃសហគមន៍ព្រៃឈើទំពជាង** ថ្ងៃ០៣ ឆ្នាំ ២០២០ សហគមន៍ព្រៃឈើទំពជាង
- **ការធ្វើវិសោធនកម្មច្បាប់ព្រៃឈើនឹងត្រូវធ្វើនៅមុនឆ្នាំ** ២០២៣ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៨ ខ្មែរថៃម
- **គេហទំព័រ** INBAR
- **ការគូសផែនទីនៃដំណើរការពាណិជ្ជកម្មកម្ពុជា៖ ផែនទីដំណើរការ និងវិភាគ (លទ្ធផលបឋម)** ឆ្នាំ២០០៩ WB / EMC

- **សហគ្រាសអនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានបង្កើតជាការលើកទឹកចិត្តសម្រាប់ការការពារសង្គម និងបរិស្ថាន (អត្ថបទសារព័ត៌មាន)** ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៩ NTFP-EP
- **ការបន្ថែមគុណតម្លៃរបស់អនុផលព្រៃឈើដើម្បី ប្រយោជន៍ដែលបានបង្កើន ដល់ប្រជាជននៅជនបទ៖ ការស្រាវជ្រាវសេដ្ឋកិច្ច និងគោលនយោបាយស្តីពីផលិតផលអនុផលព្រៃឈើនៅកម្ពុជា** ខែឧសភាឆ្នាំ ២០១៧ Emmanuelle Andaya និង ខូ អៀងហួត , UNDP
- **សិក្សាគោលនយោបាយរបស់អនុផលព្រៃឈើ កម្ពុជា** កាលបរិច្ឆេទគ្មាន NTFP-EP និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ SDC
- **របាយការណ៍ (Proceding Report) ប្រជុំប្រចាំឆ្នាំរបស់ក្រុមការងារ** NTFP **កម្ពុជា / បទបង្ហាញជា** Power Point របស់លោកគឹម សារិន អនុប្រធាន នាយកដ្ឋានជីវភាព ១៩ មករា ២០២១, NTFP-EP
- **ការវិភាគអំពីការខ្វះចន្លោះគោលនយោបាយ ស្តីពីការធ្វើពាណិជ្ជកម្មផ្តៅនៅកម្ពុជា** ក្រុមគ្រប់គ្រងផ្តៅ / រស់ សុដ្ឋា ខែមិថុនា ឆ្នាំ២០១០
- **របាយការណ៍ទីប្រឹក្សាឯករាជ្យផ្នែកគោលនយោបាយ៖ ធាតុចូលបន្ថែម** មិថុនា ២០១៤, WWF, រស់ សុដ្ឋា
- **បឋមស្តីពីអនុផលព្រៃឈើនៅកម្ពុជា** ឆ្នាំ ២០១៥ NTFP-EP, WWF, Wild Wild, Both ENDS, SIDA, USAID
- **របាយការណ៍ (Proceeding Report) ស្តីពីសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការលើកលែងពន្ធលើអនុផលព្រៃឈើ,** ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២០, **NTFP-EP, WWF,** វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ក្រុមការងារ NTFP កម្ពុជា
- **របាយការណ៍ស្តីពី ក្រុមការងារពង្រឹងពាណិជ្ជកម្ម និងគោលនយោបាយផ្តៅ "គម្រោងសាកល្បងការអនុវត្តគោលនយោបាយ"** ខែមេសា ឆ្នាំ២០១១ ក្រុមគ្រប់គ្រងផ្តៅ/រស់ សុដ្ឋា អង្គការ **WWF** ។
- **សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីវិស័យព្រៃឈើជាតិ** ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០២ ។
- **របាយការណ៍បច្ចុប្បន្នភាព ស្តីពី CF/CPA តាមបណ្តាខេត្ត** (រហូតដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៩), រដ្ឋបាលព្រៃឈើ/MAFF និងក្រសួងបរិស្ថាន

- **ហេតុអ្វីឫស្សី? ដំណោះស្រាយបៃតង** គ្មានកាលបរិច្ឆេទ ឫស្សី DWIS, https://lewisbamboo.com/why-bamboo-green-solution/

## ឧបសម្ព័ន្ធ ២៖ បញ្ជីបុគ្គលគន្លឹះដែលបានសម្ភាស

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្ថាប័ន | ទីតាំង |
|---|---|---|---|---|---|
| 1 | ម៉េង ឡូត | ប្រុស | អ្នកសម្របសម្រួលបណ្ដាញCSO-REDD+ | វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា | ភ្នំពេញ |
| 2 | ឡុង រត្តនៈកុមារ | ប្រុស | អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ, MAFF | ភ្នំពេញ |
| 3 | សឹម សុម៉េង | ប្រុស | ប្រធានការិយាយល័យ | ការិយាល័យនាំចូលនិងនាំចេញ, ឧស្សាហកម្មព្រៃឈើ, រដ្ឋបាលព្រៃឈើ, MAFF | ភ្នំពេញ |
| 4 | ប៉ោវ ចាន់លុនឌី | ប្រុស | មន្ត្រីព័ត៌មាន | អគ្គនាយកដ្ឋានគយនិងរដ្ឋាករ | ភ្នំពេញ |
| 5 | លីវ ឡុងឌី | ប្រុស | អនុប្រធានការិយាល័យ | សេវាកម្មច្រកចេញចូលតែមួយ ខន្ធមានជ័យរាជធានីភ្នំពេញ (មកពីក្រសួងពាណិជ្ជកម្ម) | ភ្នំពេញ |
| 6 | គឹម សារិន | ប្រុស | អនុប្រធាន | នាយកដ្ឋានជីវភាពសហគមន៍ ក្រសួងបរិស្ថាន | ភ្នំពេញ |
| 7 | រស់ ជ័រ | ប្រុស | ប្រធាន | នាយកដ្ឋានជីវភាពសហគមន៍ ក្រសួងបរិស្ថាន | ភ្នំពេញ |

| | | | | | |
|---|---|---|---|---|---|
| 8 | Richard Dansey | ប្រុស | នាយក | LEOPA BAMBOO | ភ្នំពេញ |
| 9 | ជ័យ គូឡាំង | ប្រុស | ប្រធានគម្រោង ផ្តៅ/ឫស្សី | WWF | ភ្នំពេញ |
| 10 | ឆឹង សុរិរិយ៉ា | ប្រុស | ប្រធានគោលនយោបាយ | NTFP-EP | ភ្នំពេញ |
| 11 | ខៀវ សំណាង | ប្រុស | អ្នកឯកទេសខាងការភ្ជាប់ជាមួយផ្នែកឯកជន | WCS | ភ្នំពេញ |
| 12 | ឡាយ សុវត្ថារ៉ា | ប្រុស | ប្រធានគម្រោងទទួលបានយុត្តិធម៌ និងអភិបាលកិច្ច | CLEC | ភ្នំពេញ |
| 13 | សុវណ្ណ ពិសិដ្ឋ | ប្រុស | នាយក | RAC | ភ្នំពេញ |
| 14 | ដួង ម៉ាល័យ | ស្រី | ម្ចាស់សិប្បកម្ម | សិប្បកម្មគុយម៉េង | ព្រៃនប់ ខេត្តព្រះសីហនុ |
| 15 | ស៊ឹក អ៊ីស៊ា | ប្រុស | ម្ចាស់សិប្បកម្ម | សប្បកម្មម្លប់ឫស្សី | ចាន់គៀក អូរឫស្សី កំពង់ត្រឡាច កំពង់ឆ្នាំ |
| 16 | យុត ភាង | ស្រី | ប្រធាន | សហគមន៍តំបន់ការពារធម្មជាតិ ទ័ពជាង | បាក់អង្រ្រត់ ដងពែង ស្រែអំបិល កោះកុង |
| 17 | ឡុង ថេត | ប្រុស | អតីតប្រធាន | សហគមន៍តំបន់ការពារធម្មជាតិ ទ័ពជាង | បាក់អង្រ្រត់ ដងពែង ស្រែអំបិល កោះកុង |
| 18 | ឆេង អូន | ស្រី | បេឡាករ | សហគមន៍តំបន់ការពារធម្មជាតិ ទ័ពជាង | បាក់អង្រ្រត់ ដងពែង ស្រែ |

| | | | | | |
|---|---|---|---|---|---|
| | | | | | អំបិល<br>កោះកុង |
| 19 | គង់ ភា | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើ ព្រៃដំណាក់ | ស្រែសំរោង<br>ស្រែសំរោង ជុំគិរី កំពត |
| 20 | ម៉ែន នៅ | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើព្រៃខ្មៅ | ព្រៃខ្មៅ ស្រែក្នុង<br>ជុំគិរី កំពត |
| 21 | ខែម ម៉ាលី | ស្រី | បេឡាករ | សហគមន៍ព្រៃឈើព្រៃខ្មៅ | ព្រៃខ្មៅ ស្រែក្នុង<br>ជុំគិរី កំពត |
| 22 | សឿម សែម | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើដូង | ដូង អង្គរជ័យ<br>កំពត |
| 23 | ញ៉ែម ញ៉ាន | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើ<br>ជ្រោះស្តី | គាថាវង្សលើ<br>ត្រពាំងសាលាកើត<br>បន្ទាយមាស<br>កំពត |
| 24 | អ៊ុ មនោ | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើ<br>ជ្រួយថ្លា | ត្រាំសសរ<br>សំរោងលើ<br>បន្ទាយមាស<br>កំពត |
| 25 | ហុង សុខឿន | ស្រី | ប្រធាន | សហគមន៍ព្រៃឈើ<br>ជ្រៃប្រទាក់ក្រឡា | ប៉ុន ត្រពាំង<br>សាលាកើត<br>បន្ទាយមាស<br>កំពត |
| 26 | សួស ហាន | ប្រុស | ប្រធាន | សហគ្រាសកែច្នៃ<br>ទ្រាំង | សង្កែ ឆែប<br>ឆែប ព្រះវិហារ |

| | | | | | |
|---|---|---|---|---|---|
| 27 | សុខ យឿន | ស្រី | អនុប្រធាន | សហគមន៍ព្រៃឈើសង្កែ | សង្កែ ឆែប ឆែប ព្រះវិហារ |
| 28 | មាស ហា | ប្រុស | ប្រធានក្រុម | សហគ្រាសកែច្នៃទ្រាំង/សហគមន៍ព្រៃឈើសង្កែ | សង្កែ ឆែប ឆែប ព្រះវិហារ |
| 29 | ខួន វ៉ាត | ប្រុស | ប្រធាន | សហគ្រាសកែច្នៃទ្រាំង | ឆែបកើត ឃុំឆែប ស្រុកឆែប ខេត្តព្រះវិហារ |
| 30 | គង់ ទីន | ប្រុស | អតីតៈប្រធាន | សហគមន៍តំបន់ការពារធម្មជាតិឆែបកើត | ឆែបកើត ឃុំឆែប ស្រុកឆែប ខេត្តព្រះវិហារ |
| 31 | សួន ម៉ាលេត | ស្រី | បេឡាករ | សហគមន៍តំបន់ការពារធម្មជាតិឆែបកើត | ឆែបកើត ឃុំឆែប ស្រុកឆែប ខេត្តព្រះវិហារ |
| 32 | ណៃ តី | ប្រុស | ប្រធាន | សហគ្រាសទឹកឃ្មុំគុណភាព២ | គុណភាព២ ឆែប២ ឆែប ព្រះវិហារ |
| 33 | ផៃ ស៊ុន | ប្រុស | ប្រធាន | គុណភាព២ | គុណភាព២ ឆែប២ ឆែប ព្រះវិហារ |
| 34 | ឡេង រ៉ា | ប្រុស | សមាជិក | សហគ្រាសទឹកឃ្មុំគុណភាព២ | គុណភាព២ ឆែប២ ឆែប ព្រះវិហារ |
| 35 | ពាង ខឿប | ប្រុស | នគបាលឃុំ | នគបាលឃុំឆែប | គុណភាព២ ឆែប២ ឆែប ព្រះវិហារ |

| | | | | | |
|---|---|---|---|---|---|
| 36 | Roeung Ream | ប្រុស | ប្រធាន | សហគមន៍ព្រៃឈើ គុណភាព ១ | គុណភាព១ ឆែប២ ឆែប ព្រះវិហារ |
| 37 | គុច ស | ប្រុស | ប្រធានភូមិ | គុណភាព១ | គុណភាព១ ឆែប២ ឆែប ព្រះវិហារ |
| 38 | ខន សុខុម | ប្រុស | ទីផ្សារ | សហគ្រាសទឹកឃ្មុំពូជ្រី | ពូតាំង ពូជ្រី ពេជ្រជ្រាដា មណ្ឌលគិរី |
| 39 | កេញ សុផាត | ប្រុស | ប្រធាន | សហគ្រាសទឹកឃ្មុំ ពូជ្រី/MFV | ពូតាំង ពូជ្រី ពេជ្រជ្រាដា មណ្ឌលគិរី |
| 40 | ងើល ងី | ប្រុស | ប្រធាន | សហគមន៍តំបន់ការពារធម្មជាតិ ជីខ្លប | ជីខ្លប សុខសាន កោះញែក មណ្ឌលគិរី |
| 41 | ស៊ាត សត | ស្រី | អនុប្រធាន | សហគ្រាសកែច្នៃឫស្សី អរប្ញូនលើ | អូរប្ញូនលើ អូរប្ញូនលើ កោះញែក មណ្ឌលគិរី |
| 42 | ផាន ស្រីមុំ | ស្រី | សមាជិក | សហគមន៍តំបន់ការពារធម្មជាតិ អរប្ញូនលើ | អូរប្ញូនលើ អូរប្ញូនលើ កោះញែក មណ្ឌលគិរី |
| 43 | សៃ ស្រីនិច | ស្រី | លេខាធិការ | សហគមន៍តំបន់ការពារធម្មជាតិ អរប្ញូនលើ | អូរប្ញូនលើ អូរប្ញូនលើ កោះញែក មណ្ឌលគិរី |

# ឧបសម្ព័ន្ធ៣៖ បញ្ជីវត្តមានក្រុមពិភាក្សា

| No. | ឈ្មោះ | ភេទ | មុខនាទី | ឈ្មោះសហគមន៍ | ទូរស័ព្ទ |
|---|---|---|---|---|---|
| | **សហគមន៍ព្រៃឈើព្រៃខ្មៅ ( កំពត )** | | | | |
| 1 | ម៉ែន ណាវ | ប | ប្រធាន | សហគមន៍ព្រៃខ្មៅ ( កំពត ) | 088 463 2749 |
| 2 | អោង ធឿន | ប | សមាជិក | សហគមន៍ព្រៃខ្មៅ | 097 432 2194 |
| 3 | ខឹម សុម៉ាលី | ស | ហិរញ្ញិក | សហគមន៍ព្រៃខ្មៅ | 088 514 1296 |
| 4 | ឈួន ធី | ប | សមាជិក | សហគមន៍ព្រៃខ្មៅ | 088 725 1620 |
| 5 | សុក ខន | ប | សមាជិក | សហគមន៍ព្រៃខ្មៅ | អត់មានលេខ |
| 6 | កឹម ទូច | ប | លេខា | សហគមន៍ត្រពាំងឈើទាល ដំណាក់រលុះ | អត់មានលេខ |
| 7 | គង់ ភា | ប | ប្រធាន | សហគមន៍ធ្លកយុលដំណាក់រលុះ | 096 929 8401 |
| 8 | ខែម ទូច | ប | អនុ.ប្រធាន | សហគមន៍ច្រេសដំណាក់រលុះ | 097 525 0216 |
| | **សហគមន៍ដើមដូង (កំពត)** | | | | |
| 9 | ស៊ឹម សែម | ប | ប្រធាន | សហគមន៍ដើមដូង | 097 681 1952 |
| 10 | កាក់ ធូ | ស | សមាជិក | សហគមន៍ដើមដូង | |
| 11 | ញ៉ែម គឹមឃីម | ស | សមាជិក | សហគមន៍ដើមដូង | 097 788 6916 |
| 12 | ស៊ឹម ចាន់ថៃ | ស | សមាជិក | សហគមន៍ដើមដូង | |
| 13 | ជា ចាត | ប | ប្រធាន | សហគមន៍ម្រោម | 088 512 5588 |
| 14 | ជុំ សុភារ៉េត | ប | សមាជិក | សហគមន៍ម្រោម | |
| 15 | ជុំ សុភារម្យ | ប | សមាជិក | សហគមន៍ម្រោម | |
| 16 | ឃុត ហាម | ប | ប្រធាន | សហគមន៍ដូនបុណ្យ | 097 475 3214 |
| 17 | ញ៉ែម ញ៉ាន | ប | អនុប្រធាន | សហគមន៍ដូនបុណ្យ | 088 733 8040 |
| 18 | ឃុត រឿន | ស | សមាជិក | សហគមន៍ដូនបុណ្យ | |
| 19 | វេក ចាន់ណារី | ស | សមាជិក | សហគមន៍ដូនបុណ្យ | |
| 20 | ប្ញូន ប្រុស | ប | ប្រធាន | សហគមន៍ជ្រោះស្តី | 088 442 5269 |
| 21 | ជឹម ចំរើន | ស | សមាជិក | សហគមន៍ជ្រោះស្តី | |

| | | | | | |
|---|---|---|---|---|---|
| 22 | អ៊ុក សំណាង | ប | សមាជិក | សហគមន៍ជ្រោះស្តី | 097 207 5026 |
| 23 | ហាង់ សុឃឿន | ស | សមាជិក | សហគមន៍ជ្រៃប្រទាក់ក្រឡា | |
| 24 | រិន មុំ | ស | សមាជិក | សហគមន៍ជ្រៃប្រទាក់ក្រឡា | 071638 0519 |
| | **សហគមន៍ពូជ្រី ឬក្អែម (មណ្ឌលគិរី)** | | | | |
| 25 | កើញ បូផាត់ | ប | ប្រធាន | សហគមន៍ក្អែម( ឃុំ ) | 097 745 505 |
| 26 | ចិត្ត កាក់ | ប | អនុប្រធាន | សហគមន៍ក្អែម( ឃុំ ) | |
| 27 | ខន សុខុម | ប | ទីផ្សារ | សហគមន៍ក្អែម( ឃុំ ) | |
| | **សហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹម (មណ្ឌលគិរី)** | | | | |
| 28 | ភើល ងិ | ប | ប្រធាន | សហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹម | 071 727 7311 |
| 29 | ដាត់ ចាន់ថៃ | ប | លេខា | សហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹម | 097 983 7747 |
| 30 | សាង ត្រម | ប | អនុប្រធាន | សហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹម | 097 806 1990 |
| 31 | យុទ្ធ គិ | ប | គណៈកម្មការ | សហគមន៍ជីក្លប់ភ្នំជួងក្តីសង្ឃឹម | 066 922 970 |
| | | | | សហគមន៍អរបូនលើ(មណ្ឌលគិរី) | |
| 32 | បឿន ង៉ែត | ប | ប្រធាន | សហគមន៍អរបូនលើ | 097 424 9254 |
| 33 | សៃ ស្រីនិច | ស | លេខា | សហគមន៍អរបូនលើ | 097 880 9163 |
| 34 | ស៊ាត ស៊ុត | ប | គណៈកម្មការ | សហគមន៍អរបូនលើ | 088 516 0777 |
| 35 | អ៊ី អុល | ប | គណៈកម្មការ | សហគមន៍អរបូនលើ | 097 785 1000 |
| 36 | ធឿន ស្រីរ័ត | ស | គណៈកម្មការ | សហគមន៍អរបូនលើ | 097 902 2477 |
| 37 | ផាន ស្រីណាយ | ស | គណៈកម្មការ | សហគមន៍អរបូនលើ | 097 900 7376 |
| | **សហគមន៍ព្រៃឈើគុណភាព១ ឬ ប្រា (ព្រះវិហារ)** | | | | |
| 38 | សាត សោន | ប | ប្រធាន | សហគមន៍ព្រៃឈើគុណភាព១ | 088 391 0023 |
| 39 | ញ៉ង សែម | ប | អនុប្រធាន | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |
| 40 | សោម សឿង | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |
| 41 | រឿង រៀម | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | 088 392 3963 |
| 42 | សុខ សាត់ | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |
| 43 | ហែម ចឿង | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |
| 44 | ចែវ ផាត់ | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |
| 45 | ហែម ហឿត | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព១ | អត់មានលេខ |

| | | | | | |
|---|---|---|---|---|---|
| 46 | យុន ខុំ | ប | មន្ត្រីប៉ុស្ត | ភូមិផែប២ | 097 753 8997 |
| 47 | គុជ សូរ | ប | ប្រធានភូមិ | ភូមិផែប ឃុំផែប ស្រុកផែប | 088 940 6069 |
| 48 | មុំ អួង | ប | អនុភូមិ | ភូមិផែប ឃុំផែប ស្រុកផែប | 097 803 7299 |
| | **សហគមន៍ព្រៃឈើគុណភាព២ (ព្រះវិហារ)** | | | | |
| 49 | ណៃ គី | ប | ប្រធាន | សហគមន៍ព្រៃឈើគុណភាព២ | 088 474 2428 |
| 50 | រឿង ស៊ុំ | ប | បេឡា | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 51 | គី យឺន | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 52 | យួន សារឹម | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 53 | ឡេង រ៉ា | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | 097 334 4609 |
| 54 | នុន និត | ស | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 55 | សោម ស | ស | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 56 | សឹម រឿន | ប | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 57 | ខឿប កង | ស | សមាជិក | សហគមន៍ព្រៃឈើគុណភាព២ | អត់មានលេខ |
| 58 | ផាយ ស៊ុន | ប | មេភូមិ | ភូមិប្រា ឃុំផែប២ ស្រុកផែប | 097 878 4372 |
| 59 | នី គង់ | ប | អនុភូមិ | ភូមិប្រា ឃុំផែប២ ស្រុកផែប | 096 753 1877 |
| 60 | ពាង ខឿប | ប | នាយរងប៉ុស្ត | ឃុំផែប២ | 097 262 7749 |
| | **សហគមន៍សង្កែ១ (ព្រះវិហារ)** | | | | |
| 61 | សុខ ឃឿន | ស | អនុប្រធាន | សហគមន៍សង្កែ១ | 088 519 1244 |
| 62 | ឡាន់ លឿត | ស | សមាជិក | សហគមន៍សង្កែ១ | |
| 63 | ស្អាយ សាន | ស | សមាជិក | សហគមន៍សង្កែ១ | |
| 64 | ជា សុន | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | |
| 65 | សួស ហាន | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | 086 838 710 |
| 66 | សេង តាប់រ៉ា | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | |
| 67 | អ៊ិន ស៊ុំ | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | |
| 68 | ទិត យឺន | ប | កែច្នៃរែក | សហគមន៍សង្កែ១ | |
| 69 |ការ ជួន | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | |
| 70 | ពុធ សារ៉ាន់ | ប | កែច្នៃចង្កឹះទ្រាំង | សហគមន៍សង្កែ១ | |

| | | | | | |
|---|---|---|---|---|---|
| 71 | មាស ហឿ | ប | ប្រធានក្រុមកែច្នៃទ្រាំង | សហគមន៍សង្កែ១ | 097 279 7293 |
| | **សហគមន៍កែច្នៃចង្កឹះឆែប១ (ព្រះវិហារ)** | | | | |
| 72 | យូន វ៉ាត់ | ប | ប្រធានកែច្នៃចង្កឹះ | សហគមន៍កែច្នៃចង្កឹះឆែប១ | 097 616 3274 |
| 73 | សួស វ៉ាត់ | ប | អនុប្រធានកែច្នៃចង្កឹះ | សហគមន៍កែច្នៃចង្កឹះឆែប១ | |
| 74 | សូ មុំ | ប | សមាជិក | សហគមន៍កែច្នៃចង្កឹះឆែប១ | |
| 75 | សូ ហួន | ប | សមាជិក | សហគមន៍កែច្នៃចង្កឹះឆែប១ | |
| 76 | គង ជិន | ប | សមាជិក | សហគមន៍កែច្នៃចង្កឹះឆែប១ | |
| 77 | សួន ឡេត | ស | សមាជិក | សហគមន៍ព្រៃឈើឆែប១ | |
| 78 | វ៉ាន់ ឡូត | ស | សមាជិក | សហគមន៍ព្រៃឈើឆែប១ | |
| 79 | គង់ ថិន | ប | សមាជិក | សហគមន៍ព្រៃឈើឆែប១ | 097 302 4965 |
| | **សហគមន៍តំបន់ការពារធម្មជាតិភ្នំទ័ពជាង ( កោះកុង )** | | | | |
| 80 | យុត គៀង | ប | ប្រធាន | សហគមន៍ភ្នំទ័ពជាង ( កោះកុង ) | 088 271 4110 |
| 81 | ចេង អួន | ស | ខាងទីផ្សារ | សហគមន៍ភ្នំទ័ពជាង | 096 713 1739 |
| 82 | ម៉ា សៃ | ស | ប្រធានកែច្នៃ | សហគមន៍ភ្នំទ័ពជាង | 010 824 733 |
| 83 | យ៉ាំ ផេន | ប | សមាជិក | សហគមន៍ភ្នំទ័ពជាង | 086 561 802 |
| 84 | អុន បូរី | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | 015 811 807 |
| 85 | នួន ភឺន | ប | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 86 | នួន គង់ | ប | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 87 | ឡាច មោក | ប | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 88 | សែម សេម | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 89 | ចេង សំអាត | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 90 | ពុធ ឃឿន | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 91 | យុត ធន់ | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | |
| 92 | ចេង សារី | ស | សមាជិក | សហគមន៍ភ្នំទ័ពជាង | |

| | | | | | |
|---|---|---|---|---|---|
| 93 | ឡុង ថេត | ប | ប្រធានសហគមន៍ | សហគមន៍ព្រៃឈើទំពជាង | 0968079601 |

## ឧបសម្ព័ន្ធ៤ ៖ ដំណើរការជាក់ស្ដែងក្នុងការស្នើសុំនាំចេញផលិតផលអនុផលព្រៃឈើ

### ផ្អែកលើព័ត៌មានមិនផ្លូវការដែលផ្ដល់ដោយការិយាល័យនាំចូល / នាំចេញ រដ្ឋបាលព្រៃឈើ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

របាយការណ៍មិនមានចេតនាផ្ដល់ព័ត៌មានលម្អិតអំពីជំហាននីមួយៗក្នុងការស្នើសុំនាំចេញទេ តែផ្ទុយទៅវិញវាប្រាប់យើង ថាតើមានជំហានប៉ុន្មានដែលត្រូវបានអនុវត្តដើម្បីបានជាគំនិត។ សរុបដោយផ្អែកលើបទពិសោធន៍ជាក់ស្ដែងមាន ១៧ ជំហានដែលត្រូវធ្វើមុនពេលនាំចេញ៖

1) ក្រុមហ៊ុនដាក់ពាក្យស្នើសុំនាំចេញ។
2) លេខាធិការនៃប្រតិភូនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទគឺរដ្ឋបាលព្រៃឈើធ្វើការដើម្បីចាត់ចែងដំណើរការពាក្យស្នើសុំ។
3) បន្ទាប់មកពាក្យស្នើសុំត្រូវបានបញ្ជូនទៅនាយកដ្ឋានបច្ចេកទេស។
4) ពាក្យស្នើសុំ ដែលបានផ្ញើទៅការិយាល័យនាំចូល និងនាំចេញនៃរដ្ឋបាលហិរញ្ញវត្ថុ
5) ពាក្យស្នើសុំដាក់ជូនទៅអនុប្រធាននាយកដ្ឋាននាំចូល និងនាំចេញនៃរដ្ឋាបាលព្រៃឈើ។
6) ពាក្យស្នើសុំត្រូវបានពិនិត្យ និងបញ្ជូនទៅប្រធាននាយកដ្ឋាននាំចូលនិងនាំចេញ។
7) ពាក្យសុំត្រូវបានឯកភាព និងបញ្ជូនទៅប្រតិភូអគ្គនាយករងរដ្ឋបាលព្រៃឈើធ្វើការយល់ព្រម និងចាត់ចែងបញ្ជូនមន្ត្រីទៅមើលផលិតផលសុំនាំចេញ
8) មន្ត្រីទាំងនោះចុះទៅមើលផលិតផលដែលបានស្នើសុំនាំចេញ។
9) មន្ត្រីធ្វើរបាយការណ៍។
10) ក្នុងករណីដែលត្រូវបានអនុញ្ញាតឱ្យបន្តទៅមុខទៀតរដ្ឋមន្ត្រី បានផ្ញើលិខិតមួយច្បាប់ទៅទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីការឯកភាពលើគ្រប់ប្រភេទនៃផលិតផលឈើ និងអនុផលព្រៃឈើទាំងអស់។

11) ប្រសិនបើទីស្តីការគណៈរដ្ឋមន្ត្រីបានយល់ព្រម ទីស្តីការគណៈរដ្ឋមន្ត្រីផ្ញើលិខិតជូនត្រលប់ទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ។
12) ផ្អែកលើលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើលិខិតមួយទៅក្រសួងពាណិជ្ជកម្មដើម្បីសុំការបើកផ្លូវ សម្រាប់ការនាំចេញ។
13) ដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចេញ (ប្រើសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាឯកសារយោង) ។
14) ក្រុមហ៊ុនបង់ថ្លៃកម្រៃជើងសា (១%) នៃថ្លៃផលិតផលនីមួយៗ។
15) ក្រសួងពាណិជ្ជកម្មវាយតម្លៃសំណើសម្រាប់នាំចេញ។
16) ក្រុមហ៊ុនរៀបចំបង់ពន្ធគយ។ និង
17) ចាត់ចែងការនាំចេញដោយធ្វើការស្នើសុំលិខិតអនុញ្ញាតដឹកជញ្ជូន។

## ឧបសម្ព័ន្ធ៥ ៖ ព័ត៌មានបន្ថែមអំពីចំណូលពីអនុផលផ្សេងៗទៀត

អនុផលព្រៃឈើបានបម្រើយ៉ាងសំខាន់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសពលរដ្ឋនៅតាមជនបទដូចដែលបានរៀបរាប់ នៅដើមនៃរបាយការណ៍នេះ។ ផ្អែកលើការសិក្សានាពេលថ្មីៗនេះ គឺឆ្នាំ២០២០ អនុផលព្រៃឈើបានចូលរួមចំណែករហូតដល់ទៅ ៥0% នៃជីវភាពរបស់សហគមន៍មូលដ្ឋាន។

រុក្ខជាតិវេជ្ជសាស្ត្រ៖ របាយការណ៍ដដែលក៏បានលើកឡើងថាប្រជាជនកម្ពុជាជាង ៤0% ប្រើប្រាស់រុក្ខជាតិវេជ្ជសាស្ត្រ។ ដូច្នេះតាមការប៉ាន់ប្រមាណប្រាក់ចំណូល ដែលទទួលបានពីផ្នែកនេះអាចចូលរួមវិភាគទានរហូតដល់ ៥,៦ លានដុល្លារ អាមេរិកដល់ជីវភាពរស់នៅនៅតាមជនបទ។[17]

បន្លែព្រៃ៖ លើសពីនេះទៀត CFs និង CPAs ក៏មានបន្លែព្រៃដែលគួរ ឱ្យទាក់ទាញ និងមិនទាន់បម្រើសេចក្តីត្រូវការទីផ្សារបានគ្រប់គ្រាន់នៅឡើយទេ។ ឧទាហរណ៍ដោយផ្អែកលើក្រុមពិភាក្សាជាមួយ CPA ជីខ្លប នៅខេត្តមណ្ឌលគិរី សមាជិកសហគមន៍ ១០០នាក់ រកបាន ១.២២០ ដុល្លារដោយគ្រាន់តែលក់តែប្រភេទផ្សិតប៉ក់ ក្នុងឆ្នាំ ២០១៩ ។[18]

ខាងក្រោមនេះជាព័ត៌មានសំខាន់ៗមួយចំនួនអំពីប្រាក់ចំណូលដែលប្រមូលបានពីការប្រមូលអនុផលព្រៃឈើដែលត្រូវបានសិក្សាដោយ នាយកដ្ឋានជីវភាពសហគមន៍ នៃក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ ដែលបានបង្ហាញតាមរយៈ Power Point របស់ លោកគឹម សារិន អនុប្រធាន

---

[17] របាយការណ៍សង្ខេបនៃរបាយការណ៍ស្រាវជ្រាវរបស់ UNDP ស្តីពីការបន្ថែមតម្លៃអនុផលព្រៃឈើសម្រាប់អត្ថប្រយោជន៍បានបង្កើនដល់ប្រជាពលរដ្ឋ ជនបទឆ្នាំ ២០១៧ ដោយ Emmanuelle Andaya និង ខូ អៀងហួត។

[18] តាមពិតមានផ្សិតព្រៃមានតម្លៃល្អខុសៗគ្នាដែលអាចរកបាននៅក្នុងព្រៃសហគមន៍ CF / CPA ។

នាយកដ្ឋាន ក្នុងអំឡុងពេលប្រជុំប្រចាំឆ្នាំនៃក្រុមការងារ NTFP កម្ពុជា (CNWG) សម្រប សម្រួល និងរៀបចំដោយ NTFP-EP:

i. ចំណែកអនុផលព្រៃឈើសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត៖ អនុផលព្រៃឈើគឺជាចំណែកសំខាន់បំផុតសម្រាប់ជីវភាពរស់នៅរបស់សហគមន៍ដោយសារវាបានចូលរួមចំណែករហូតដល់ ៥០% ថែមទៅលើ៖ ការចិញ្ចឹមសត្វ ២៥% ស្រូវ ១៥ % ដំឡូងមី ៥ % និងផ្សេងៗទៀត ៥ %។ នេះផ្អែកលើការសិក្សាលើ ១១៨ គ្រួសាររបស់សហគមន៍តំបន់ការពារធម្មជាតិព្រៃក្លា ភូមិកំពេញ ឃុំយ៉ាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលគ្រប់គ្រងផ្ទៃដីព្រៃឈើដែលបានអនុញ្ញាតចំនួន ១. ១៩០ ហិកតា។ ចំណូលមធ្យមរបស់សហគមន៍ក្នុងឆ្នាំ ២០២០ ដែលបានពីការលក់អនុផលព្រៃឈើចំនួន១២ប្រភេទផ្សេងៗគ្នា ដូចជាបន្លែព្រៃ ជ័រទឹក ឃ្មុំជាដើម និងសត្វល្អិតមួយប្រភេទបាន ១៥១.០០០ ដុល្លារ។

ii. គ្រាប់សំរង៖ សហគមន៍ការពារធម្មជាតិអូរទុង ដែលមានទីតាំងនៅឃុំកុកឡាក់ ស្រុកវីនសៃ ខេត្តរតនគិរី រកចំណូលបាន ៥២០.០០០ ដុល្លារក្នុងមួយឆ្នាំពីការលក់គ្រាប់សំរង។[19]

iii. ផ្កាព្រៃ ១០០គុណ៖ សហគមន៍ការពារធម្មជាតិអូរជាំ នៃភូមិអូរជាំលើ និងអូរជាំក្រោម ឃុំកំពង់ ស្រុកសំឡូត និងខេត្តបាត់ដំបង រកបានជាមធ្យម ២៨. ៣១៧ដុល្លារក្នុងមួយឆ្នាំពីការលក់ផ្កា១០០គុណ។ សហគមន៍មាន ៤៣០ គ្រួសារ និង ២៥៨ គ្រួសារនៃពួកគាត់ ប្រមូលផ្កានេះលក់។

iv. ករណីជ័រទឹក៖ សហគមន៍តំបន់ការពារធម្មជាតិដងផ្លេត ភូមិដងផ្លេត ស្រុកឆែប២ ខេត្តព្រះវិហារ ជាមធ្យមប្រជាពលរដ្ឋរកបានប្រាក់២៤១.៨៣២ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ សហគមន៍មាន ៣០៧ គ្រួសារ និងមានដើមជ័រច្បោះ ២៧.១២០ ដើម។

---

[19] ជាផ្លែព្រៃមួយប្រភេទដែលត្រូវបានប្រើដោយប្រជាពលរដ្ឋក្នុងតំបន់សម្រាប់ធ្វើបង្អែម និងឱសថបុរាណ។

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ **ngoforum@ngoforum.org.kh**
គេហទំព័រៈ **www.ngoforum.org.kh**